

# ការស្ទង់មតិក្នុង
# រាជធានីភ្នំពេញ ឆ្នាំ២០២៣

---

## ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងរាជធានីភ្នំពេញ

អង្គការសហគមន៍ធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

# ការស្ទង់មតិក្នុង
# រាជធានីភ្នំពេញ ឆ្នាំ២០២៣


**អង្គការសហគមធាងត្នោត**

អាសយដ្ឋាន៖ ផ្ទះលេខ ៧ ផ្លូវលេខ៤៩៤ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ៤៣១ ៥៥៥
អ៊ីមែ៉ល៖ info@teangtnaut.org
គេហទំព័រ៖ www.teangtnaut.org and www.urbanvoicecambodia.net
ហ្វេសប៊ុក៖ https://www.facebook.com/sttcambodia/



បោះពុម្ពផ្សាយ ខែកញ្ញា ឆ្នាំ២០២៣

អង្គការសហគមធាងត្នោត
Sahmakum Teang Tnaut Organization - a Cambodian Urban NGO

# មាតិកា

**មាតិកា**........................................................................................i
**បញ្ជីតារាង និងបញ្ជីក្រាហ្វិក**.......................................................................iii
**១.សេចក្តីផ្តើម**........................................................................................១
**២. វិធីសាស្ត្រ**........................................................................................៤
គោលបំណង........................................................................................៤
ការប្រមូលទិន្នន័យបឋម-ការស្ទង់មតិ........................................................................................៤
និយមន័យនៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង........................................................................................៥
ក្រមសីលធម៌នៃការស្រាវជ្រាវ........................................................................................៦
ការត្រួតពិនិត្យគុណភាព........................................................................................៧
ទិន្នន័យបន្ទាប់បន្សំ........................................................................................៧
វិសាលភាព និងដែនកំណត់........................................................................................៧
ទីតាំងលំនៅឋានក្រីក្រដែលមិនបានដាក់បញ្ចូល........................................................................................៧
ការយល់ដឹងរបស់អ្នកចូលរួមផ្តល់បទសម្ភាស........................................................................................៧
**ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជន**........................................................................................៧
**៣. លទ្ធផលរកឃើញសំខាន់ៗ**........................................................................................៩
ការថយចុះចំនួនទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ........................................................................................៩
លក្ខណៈរួមនៃទីតាំងលំនៅឋានក្រីក្រ........................................................................................១៥
ក្រុមជនជាតិភាគតិច........................................................................................១៥
លទ្ធផលរកឃើញសំខាន់ៗ........................................................................................១៧
**ការកាន់កាប់ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការតាំងទីលំនៅថ្មី**........................................................................................១៧
ប្រភេទដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លី........................................................................................១៧
*ប្រភេទដីធ្លី*........................................................................................*១៧*
*ប្រភេទប័ណ្ណកម្មសិទ្ធិដីធ្លី*........................................................................................*១៧*
សិទ្ធិទទួលបានលំនៅឋានសមរម្យ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី........................................................................................១៩
*ប្រភេទដីធ្លី*........................................................................................*១៩*
*ប្លង់កម្មសិទ្ធិ*........................................................................................*២០*
*ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី*........................................................................................*២១*
*សារាចរលេខ ០៣*........................................................................................*២២*

*ច្បាប់សិទ្ធិមនុស្ស*........................................................................................២៤
លទ្ធផលរកឃើញសំខាន់ៗ........................................................................................២៦
**ស្ថានភាពលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ**................................**២៦**
សិទ្ធិទទួលបានលំនៅឋានសមរម្យ-សុវត្ថិភាព សេវា និងរាជរដ្ឋាភិបាល..........................២៦
*ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋានក្រីក្រ ភ្លើងបំភ្លឺផ្លូវ*......................................២៦
*ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋានក្រីក្រ ប្រព័ន្ធលូរំដោះទឹក*................................២៧
*ប្រព័ន្ធលូរំដោះទឹក*..........................................................................................២៨
*សេវាប្រមូលសំរាម*..........................................................................................២៨
*សេវាទឹកស្អាត*.................................................................................................២៨
*សេវាអគ្គិសនី*..................................................................................................២៩
កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ.............................................................២៩
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI)......................................................................២៩
ការសន្យារបស់អាជ្ញាធរ.........................................................................................៣១
លទ្ធផលរកឃើញសំខាន់ៗ........................................................................................៣១
**៤. សេចក្តីសន្និដ្ឋាន**.........................................................................................**៣៣**
**៥. អនុសាសន៍**....................................................................................................**៣៤**
**៦. ឧបសម្ព័ន្ធទី១៖ ទម្រង់សម្រាប់ការស្ទង់មតិ**..................................................**៣៦**
**៧. ឧបសម្ព័ន្ធទី២៖ ផែនទីទីតាំងលំនៅឋានក្រីក្រ**...........................................**៥០**

# បញ្ជីតារាង និងបញ្ជីក្រាហ្វិក

## បញ្ជីតារាង


តារាងទី០១៖ ចំនួនទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចន្លោះឆ្នាំ១៩៩៧ និង២០២៣.....១២
តារាងទី០២៖ ចំនួនគ្រួសារក្រីក្រនៅរាជធានីភ្នំពេញចន្លោះឆ្នាំ១៩៩៧ និង២០២៣..................១៤
តារាងទី០៣៖ វិធីសាស្ត្រគ្រប់គ្រងសំរាម.........................................................................២៨


## បញ្ជីក្រាហ្វិក


ក្រាហ្វិកទី០១៖ សមាមាត្រនៃទីតាំងលំនៅឋាននៅខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅចន្លោះឆ្នាំ១៩៩៧-២០២៣.......................................................................................១៣
ក្រាហ្វិកទី០២៖ ទីតាំងលំនៅឋានក្រីក្រត្រូវបានបង្កើតនៅក្នុងឆ្នាំ........................................១៥
ក្រាហ្វិកទី០៣៖ ក្រុមជនជាតិភាគតិចសំខាន់ៗ.................................................................១៥
ក្រាហ្វិកទី០៤៖ ប្រភេទដីដែលបានសង់លំនៅឋាន............................................................២០
ក្រាហ្វិកទី០៥៖ ទីតាំងលំនៅឋានដែលបានចុះបញ្ជីដីធ្លីជាប្រព័ន្ធ..........................................២១
ក្រាហ្វិកទី០៦៖ មូលហេតុនៃការបណ្ដេញចេញ និងការផ្លាស់ប្តូរលំនៅឋាន..............................២២
ក្រាហ្វិកទី០៧៖ ប្រភេទនៃប្រព័ន្ធលូរំដោះទឹក....................................................................២៧
ក្រាហ្វិកទី០៨៖ លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ............២៩
ក្រាហ្វិកទី០៩៖ លទ្ធភាពទទួលបានសេវាអគ្គិសនីកម្ពុជាសម្រាប់ការប្រើប្រាស់........................២៩



# ១. សេចក្តីផ្តើម

អង្គការសមាគមធាងត្នោត មានគោលបំណង ផ្តល់ទិន្នន័យសំខាន់ៗអំពីស្ថានភាពនៃទីតាំងលំនៅឋាន ក្រីក្រក្នុងរាជធានីភ្នំពេញរៀងរាល់ ៤ ទៅ ៥ឆ្នាំម្តង។ របាយការណ៍នេះនឹងបំពេញបន្ថែមទៅលើការស្រាវជ្រាវ និងព័ត៌មានដែលត្រូវបានធ្វើឡើងក្នុងពេលកន្លងមក។ តាមរយៈការធ្វើរបៀបនេះ ទម្រង់នៃការប្រែប្រួលពី ពេលមួយទៅពេលមួយអាចត្រូវបានវាយតម្លៃ ហើយ ទិន្នន័យថ្មីៗបំផុតត្រូវបានផ្តល់ជូនសាធារណជន។ គោលបំណងរួមនៃការស្រាវជ្រាវលើទីតាំងលំនៅឋាន ក្រីក្រក្នុងទីក្រុង គឺដើម្បីរកដំណោះស្រាយលើបញ្ហា ដែលបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ។ អង្គការ សមាគមធាងត្នោតរៀបចំការស្ទង់មតិរបស់ខ្លួន ដើម្បី ផ្តល់ព័ត៌មាន ការវិភាគ និងអនុសាសន៍ជូនសាធារណជន ប្រជាជន ដែលរស់នៅទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ ក្នុងគោលបំណងជួយឱ្យទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ក្លាយជាកន្លែងរស់នៅដែលប្រសើរជាងមុន និងជួយ ប្រជាពលរដ្ឋ ដែលរស់នៅលើទីតាំងទាំងនោះឱ្យយល់ ដឹងពីសិទ្ធិរបស់ពួកគេ ជាពិសេសសិទ្ធិទទួលបាន លំនៅឋានសមរម្យ។

មានការសិក្សាសំខាន់ៗ មួយចំនួនត្រូវបានធ្វើ ឡើងស្តីពីប្រជាជនក្រីក្រ និងលំនៅឋានរបស់ពួកគេ ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ ក្នុងរយៈពេល ពីរ បី ទសវត្សរ៍កន្លងមក។ ការសិក្សាទាំងនេះបានប្រមូល ទិន្នន័យ អំពីទីតាំងលំនៅឋាននៃគ្រួសារក្រីក្រក្នុង រាជធានី ព័ត៌មានអំពីការបណ្តេញចេញ និងការគំរាម កំហែងបណ្តេញចេញ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ការចាត់ថ្នាក់ប្រភេទដីធ្លី និងព្រមទាំងស្ថានភាព សេដ្ឋកិច្ចសង្គមទូទៅ។ ការសិក្សាទាំងនេះរួមមាន៖

- **ស្ថានភាពនៃទីតាំងលំនៅឋានរបស់ប្រជាជន ក្រីក្រនៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា៖** ត្រូវបានផលិតឡើងនៅក្នុងឆ្នាំ ១៩៩៧ ដោយអង្គការសហគមន៍ដែលបច្ចុប្បន្ននេះ គេស្គាល់ថាជាសហព័ន្ធសាមគ្គីភាពអ្នក ក្រីក្រនៅទីក្រុង (SUPF)។[១] វាជាការស្ទង់មតិ ជាសាធារណៈមានលក្ខណៈទូលំទូលាយលើក ដំបូង ស្តីពីទីតាំងលំនៅឋានរបស់អ្នកក្រីក្រ នៅក្នុងរាជធានីភ្នំពេញ។ នៅពេលនោះ ទីតាំង លំនៅឋានចំនួន៣៧៩ ត្រូវបានស្ទង់មតិ និង មានប្រជាពលរដ្ឋ សរុបចំនួន ១៨០ ០០០ នាក់ នៅក្នុងរាជធានីភ្នំពេញបានរស់នៅក្នុង"ទីតាំង មិនទាន់រៀបរយ"។
- **រាជធានីភ្នំពេញ៖ សៀវភៅព័ត៌មានស្តីពីការ អភិវឌ្ឍទីក្រុង និងទីតាំងលំនៅឋានរបស់ប្រជាជន ក្រីក្រនៅរាជធានី៖** ការស្ទង់មតិនេះត្រូវបាន ធ្វើឡើងម្តងទៀត ដោយសម្ព័ន្ធសាមគ្គីភាពអ្នក ក្រីក្រក្នុងទីក្រុងនៅក្នុងឆ្នាំ២០០៣។ វាជាការ ពិនិត្យតាមដានការស្ទង់មតិដដែល ដែលបានធ្វើ ឡើងក្នុងឆ្នាំ១៩៩៧ ដែលបានបញ្ចូលទិន្នន័យ បន្ថែមពីខណ្ឌខាងក្រៅរាជធានីភ្នំពេញ។ លទ្ធផលរកឃើញសំខាន់ៗ បានបង្ហាញថា ទំហំនៃភាពក្រីក្រ គឺកាន់តែលំបាកទៅៗនៅក្នុង ខណ្ឌខាងក្រៅ ជាទីតាំងដែលលំនៅឋានថ្មីត្រូវ បានបង្កើតឡើង ហើយសហគមន៍ចំនួន៤០% ទទួលរងការគំរាមកំហែងបណ្តេញចេញ។

---

[១] ពីមុនស្ថាប័ននេះមានឈ្មោះថាសម្ព័ន្ធអ្នកតាំងទីលំនៅក្រីក្រក្នុងទីក្រុង (Squatter and Urban Poor Federation-SUPF).

- **ការស្ទង់មតិខណ្ឌទាំង៨៖ ការសិក្សាពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ៖** នៅឆ្នាំ២០០៩ អង្គការសមាគមធាងត្នោតបានធ្វើការសិក្សាស្រាវជ្រាវពីទីតាំងលំនៅឋានក្រីក្រ ក្នុងរាជធានីភ្នំពេញ ដើម្បីពង្រឹងបន្ថែមទៅលើការស្ទង់មតិដែលបានធ្វើពីមុនៗមក។ អង្គការបានរកឃើញទីតាំងលំនៅឋានក្រីក្រចំនួន ៤១០ទីតាំង ក្នុងខណ្ឌទាំង៨ ដោយមានគ្រួសារក្រីក្រសរុបចំនួន ៤០ ៥៤៨គ្រួសារ។ អ្វីដែលសំខាន់នោះគឺគេបានរកឃើញថា នៅឆ្នាំ១៩៩៧ ជិតពាក់កណ្តាលនៃប្រជាជនក្រីក្រក្នុងរាជធានីភ្នំពេញ រស់នៅក្នុងខណ្ឌខាងក្នុង ដែលចំនួននេះបានធ្លាក់ចុះជិតដល់២៥% ក្នុងឆ្នាំ២០០៩ ដែលនេះបង្ហាញពីការផ្លាស់ប្តូរទីតាំងដ៏ច្រើនរបស់អ្នកក្រីក្រនៅរាជធានីពីខណ្ឌខាងក្នុងទៅខណ្ឌខាងក្រៅ។
- **របាយការណ៍ស្ថានភាពសហគមន៍ក្រីក្រ នៅរាជធានីភ្នំពេញ៖** នៅឆ្នាំ២០១២ សាលារាជធានីភ្នំពេញ បានធ្វើការសិក្សាជាមូលដ្ឋានរបស់ខ្លួនស្តីពីស្ថានភាពសហគមន៍ក្រីក្រ ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅនៃស្ថានភាពរស់នៅ ស្ថានភាពសេដ្ឋកិច្ចសង្គម និងការផ្តល់សេវាសង្គម។ យោងតាមការសិក្សានេះ មានទីតាំងចំនួន៥១៦ នៃសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញដែលក្នុងនោះទីតាំង ចំនួន៣៤២ ត្រូវបានរៀបចំចងក្រង និងចំនួន១៧៤ មិនបានរៀបចំចងក្រង។
- **ការស្ទង់មតិនៅក្នុងរាជធានីភ្នំពេញ ការសិក្សាអំពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ៖** ការស្រាវជ្រាវនេះធ្វើឡើងដោយអង្គការសមាគមធាងត្នោតក្នុងឆ្នាំ២០១៣ និងបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៤ មានគោលបំណងធ្វើបច្ចុប្បន្នភាពការពិនិត្យអង្កេតខណ្ឌទាំង៨ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីនៃតំបន់ក្រីក្រ ក្នុងរាជធានីភ្នំពេញឱ្យបានត្រឹមត្រូវ។ ការស្ទង់មតិនេះបានបង្ហាញពីទីតាំងលំនៅឋានរបស់ប្រជាជនក្រីក្រចំនួន ៣៤០កន្លែង ដែលស្ថានភាពជីវភាពរស់នៅជារួមរបស់ពួកគេនៅតែទាមទារឱ្យមានការកែលម្អឱ្យប្រសើរឡើង។
- **ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧៖** ការស្រាវជ្រាវនេះ ធ្វើឡើងដោយអង្គការសមាគមធាងត្នោតក្នុងឆ្នាំ២០១៧ និងបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៨ មានគោលបំណងធ្វើបច្ចុប្បន្នភាពទៅលើការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ និងដើម្បីធ្វើបច្ចុប្បន្នភាពផែនទីនៃតំបន់ក្រីក្រ ក្នុងរាជធានីភ្នំពេញឱ្យបានត្រឹមត្រូវ។ ការស្ទង់មតិនេះបានបង្ហាញពីទីតាំងលំនៅឋានរបស់ប្រជាជនក្រីក្រចំនួន ២៧៧ កន្លែង ជាមួយនឹងទំនោរគួរឱ្យកត់សម្គាល់ដែលថា សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញកើតមានជាទូទៅនៅក្នុងតំបន់ខាងក្រៅច្រើនជាងតំបន់ខាងក្នុងនៃរាជធានីភ្នំពេញ។

ការស្រាវជ្រាវថ្មីៗ បំផុតរបស់អង្គការសមាគមធាងត្នោតពេល គឺការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣។ បន្តការសិក្សាស្តីពីតំបន់លំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ និងកំណត់ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ចំនួន១៩១ទីតាំងលំនៅឋានក្រីក្រ។ ការរកឃើញសំខាន់ៗត្រូវបានសិក្សាពិនិត្យបន្ថែមខាងក្រោម។ សម្រាប់ទិន្នន័យពេញលេញ ឬសម្រាប់ការឈ្វេងយល់កាន់តែច្បាស់អំពីបញ្ហាជាក់លាក់ និងទីតាំងលំនៅឋានជាក់លាក់ សូមទំនាក់ទំនងមកកាន់អង្គការសមាគមធាងត្នោតដោយផ្ទាល់។


PARKWAY

# ២. វិធីសាស្ត្រ

## គោលបំណង

របាយការណ៍នេះមានគោលបំណងដូចខាងក្រោម៖

- ធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យថ្មីអំពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ ដែលបានសិក្សាស្រាវជ្រាវកន្លងមក "ការស្ទង់មតិក្នុងរាជធានីភ្នំពេញ" របស់អង្គការសមាគមធាងត្នោតកាលពី ឆ្នាំ២០១៧ កំណត់នូវទីតាំងដែលអាចក្លាយជាទីតាំងលំនៅឋានក្រីក្រថ្មីៗបន្ថែមទៀត និងលុបចោលនូវទីតាំងលំនៅឋាន ដែលលែងជាទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានី (សូមមើលនិយមន័យខាងក្រោម)។
- ផលិតផែនទី និងធ្វើបច្ចុប្បន្នភាពឱ្យបានត្រឹមត្រូវនៃទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ។
- រៀបចំលទ្ធផលរកឃើញ និងផ្តល់អនុសាសន៍នានា ដល់ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីឱ្យមានផលវិជ្ជមានសម្រាប់ប្រជាជន ដែលមានលំនៅឋាននៅទីតាំងក្រីក្រ នៅក្នុងរាជធានីភ្នំពេញ។

## ការប្រមូលទិន្នន័យបឋម – ការស្ទង់មតិ

ការស្ទង់មតិនេះ ធ្វើឡើង ដោយផ្អែកលើវិធីសាស្ត្រដែលបានប្រើប្រាស់នៅក្នុងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ និងឆ្នាំ២០១៧ ដើម្បីអាចប្រៀបធៀបទិន្នន័យរវាងឆ្នាំ២០១៣ ឆ្នាំ២០១៧ និងឆ្នាំ ២០២២-២០២៣។ ទោះជាយ៉ាងនេះក្តី សំណួរមួយចំនួនត្រូវបានរៀបចំសម្រួល ដើម្បីឱ្យទាន់កាលកំណត់នៃការស្រាវជ្រាវ។ កម្រងសំណួរទាំងអស់បានបំប្លែងដោយប្រើកម្មវិធីប្រមូលទិន្នន័យ កូបូ (KOBO) ដែលជាកម្មវិធីប្រមូលទិន្នន័យអេឡិចត្រូនិក ដែលអាចប្រើប្រាស់ជាមួយឧបករណ៍ចល័តដូចជាទូរស័ព្ទស្មាតហ្វូន ឬថេប្លេត។ សូមមើលឧបសម្ព័ន្ធទី១ សម្រាប់បញ្ជីសំណួរដែលបានប្រើនៅក្នុងការស្រាវជ្រាវនេះ។

អ្នកប្រមូលទិន្ន័យនៃអង្គការសមាគមធាងត្នោត និងទីប្រឹក្សាបានប្រមូលទិន្នន័យទាំងនេះ។ អ្នកប្រមូលទិន្នន័យទាំងអស់ទទួលបានការបណ្តុះបណ្តាលអំពីការប្រមូលទិន្នន័យ ដោយប្រើកម្មវិធីប្រមូលទិន្នន័យអេឡិចត្រូនិច ដើម្បីអនុវត្តការស្ទង់មតិ។ កម្មវិធីនេះប្រើប្រាស់កូអរដោនេ ដែលភ្ជាប់នៅក្នុងឧបករណ៍ថេប្លេត របស់អ្នកប្រើប្រាស់ផងដែរ។ អ្នកប្រមូលទិន្នន័យបានធ្វើការជាគូ ហើយត្រូវបានផ្តល់កូអរដោនេនៃទីតាំងលំនៅឋានចំនួន ២៧៧ ទីតាំងលំនៅឋានក្រីក្រ ដែលជាផ្នែកមួយនៃការស្ទង់មតិ ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ព្រមទាំងតំបន់សំខាន់ៗ ដែលទំនងអាចផ្តល់ឱ្យយើងរកឃើញទីតាំងលំនៅឋានក្រីក្រថ្មីៗផ្សេងទៀត ឬដែលអង្គការសមាគធាងត្នោតបានកំណត់ថា មានទីតាំងលំនៅឋានក្រីក្រក្នុងរាជធានី ប៉ុន្តែមិនត្រូវបានបញ្ចូលក្នុងការស្ទង់មតិក្នុងរាជធានីភ្នំពេញមុនៗ។ អង្គការសមាគមធាងត្នោតបានផ្តល់ជំនួយដល់អ្នកប្រមូលទិន្នន័យ ក្នុងការស្វែងរកទីតាំងលំនៅឋានក្រីក្រ។ ដែនកំណត់មួយក្នុងចំណោមដែនកំណត់ជាច្រើននៃការស្ទង់មតិនេះ គឺថាការស្ទង់មតិនេះ ទំនងជាមិនបានដាក់បញ្ចូលទីតាំងលំនៅឋានក្រីក្រមួយចំនួនដែលបំពេញលក្ខណៈវិនិច្ឆ័យ ដែល

ចាត់ទុកថាជាតំបន់ទីតាំង លំនៅឋានក្រីក្រក្នុងរាជធានី ដែលជាលទ្ធផលចំនួនសរុបនៃទីតាំងលំនៅឋានក្រីក្រ នៅក្នុងការស្រាវជ្រាវនេះ អាចចាត់ទុកបានថាជាចំនួនអប្បបរមា។

ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅក្នុងរាជធានីភ្នំពេញចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២២ ដោយអ្នកប្រមូលទិន្នន័យនៅក្នុងទីតាំងលំនៅឋាន ចំនួន ១៩១ ទីតាំងលំនៅឋានក្រីក្រ ដែលត្រូវបានចាត់ទុកថាជាតំបន់ក្រីក្រក្នុងរាជធានី និងបញ្ចូលទៅក្នុងការវិភាគចុងក្រោយ។ សម្រាប់ទីតាំងលំនៅឋាននីមួយៗមេភូមិ ចៅសង្កាត់ជាក្រុមគោលដៅចម្បងសម្រាប់សម្ភាស។ ក្នុងករណីដែលមេភូមិ ឬចៅសង្កាត់មិនមានពេលវេលានោះប្រធានសហគមន៍នឹងក្លាយជាគោលដៅបន្ទាប់នៃការសម្ភាស។ ប្រសិនបើមេភូមិ ចៅសង្កាត់ និងប្រធានសហគមន៍ទាំងអស់ មិនមានពេលវេលាចូលរួមប្រជាពលរដ្ឋ នៅក្នុងទីតាំងលំនៅឋាននោះនឹងត្រូវបានសម្ភាសជំនួសវិញ។ ជាលទ្ធផលអង្គការសមាគមធាងត្នោតជឿជាក់ថា អាចមានភាពមិនត្រឹមត្រូវមួយចំនួនដោយអ្នកផ្តល់បទសម្ភាសមិនមានចម្លើយសម្រាប់សំណួរមួយចំនួនដែលបានសួរនៅក្នុងការស្ទង់មតិនេះ។

## និយមន័យនៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង

មានការប្រើពាក្យខុសគ្នាជាច្រើន អំពីប្រជាជនក្រីក្រក្នុងទីក្រុង និងលំនៅឋានរបស់ពួកគេ នៅជុំវិញពិភពលោក ប៉ុន្តែទីតាំងលំនៅឋានក្រីក្រពិបាកកំណត់និយមន័យដោយពាក្យតែមួយណាស់។ ទីតាំងលំនៅឋានមួយចំនួនអាចមានហាងទំនិញ សាលារៀន និងសេវាសង្គមផ្សេងៗទៀត។ ចំណែកឯទីតាំងលំនៅឋានមួយចំនួនទៀតអាចជាផ្ទះតូចៗជាច្រើនជាប់គ្នាដែលមិនមានសេវានានា ដូចបានរៀបរាប់ខាងលើ។

នៅកម្ពុជា រាជរដ្ឋាភិបាលធ្វើចំណាត់ថ្នាក់ប្រជាជនក្រីក្រ តាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលជាកម្មវិធីមួយរបស់រាជរដ្ឋាភិបាលដែលធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្នុងគោលបំណងផ្តល់លទ្ធភាពកាន់តែច្រើន ក្នុងការទទួលបានសេវាសាធារណៈនានា និងប្រាក់ឧបត្ថម្ភ។[២] ប៉ុន្តែការសិក្សាស្រាវជ្រាវនេះ មិនអាចប្រើប្រាស់ទិន្នន័យទាំងនោះបានទេ ពីព្រោះរហូតមកដល់ពេលនេះ ទិន្នន័យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រាប់រាជធានីភ្នំពេញនៅមិនទាន់បានធ្វើចប់សព្វគ្រប់នៅឡើយ។ ទោះបីជាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានដំណើរការបានមួយកម្រិតក៏ដោយ ក៏មិនមានភាពច្បាស់លាស់ថា បច្ចុប្បន្នកម្មវិធីនេះ កត់ត្រាទិន្នន័យអំពីប្រជាជនក្រីក្រទាំងអស់ដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញឡើយ ដូច្នេះហើយ ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣ ត្រូវបានធ្វើឡើង ដើម្បីជួយបង្កើតទិន្នន័យដែលមានប្រយោជន៍ ដែលជួយបង្ហាញថា តើក្រុមប្រជាជនក្រីក្រជាច្រើនដែលគួរតែអាចទទួលបានប័ណ្ណក្រីក្រស្ថិតនៅកន្លែងណាខ្លះក្នុងរាជធានីភ្នំពេញ។

សម្រាប់គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ និយមន័យជាមូលដ្ឋានមួយត្រូវបានប្រើប្រាស់សម្រាប់ទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ។ ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនត្រូវបានកំណត់ថាជា "សំណង់លំនៅឋានជាប់ៗគ្នាចាប់ពី ១០ខ្នង ឡើងទៅ ដែលមានរចនាសម្ព័ន្ធលំនៅឋានមានសោភ័ណភាពគុណភាពមិនល្អ និងឬលំនៅឋានដែលសាងសង់ដោយគ្មានរចនាបថច្បាស់លាស់ គ្មានក្បួនខ្នាតត្រឹមត្រូវព្រមទាំងមិនអនុលោមតាមប្លង់គោល"។[៣] លើសពីនេះទៀត សម្រាប់និយមន័យរបស់អង្គការលំនៅឋានពិភពលោកស្តីពីតំបន់មិនរៀបរយ បានផ្តល់និយមន័យបន្ថែមថា

---

[២] សូមមើល https://idpoor.gov.kh/en/.

[៣] និយមន័យនេះត្រូវបានប្រើដោយអង្គការសមាគមធាងត្នោតនៅក្នុងការស្ទង់មតិអ្នកក្រីក្រក្នុងទីក្រុងចំនួនពីរលើកមុនរបស់ខ្លួនក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១៣។ ស្រដៀងគ្នានេះដែរ វាគឺជានិយមន័យដែលប្រើដោយអង្គការយូនីសេហ្វ (UNICEF) និងអង្គការដៃគូ ភីផល អ៊ិន នីដ (People in Need-PIN)។ សូមមើលការវាយតម្លៃសូចនាករ

ប្រជាពលរដ្ឋចាប់ពីដប់គ្រួសារឡើងទៅដែលរស់នៅក្នុងលំនៅឋានដែលមិនស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ត្រូវបានចាត់ថ្នាក់ជាទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនផងដែរ។

- ជាលំនៅឋានជាប់លាប់ និងអចិន្ត្រៃយ៍ដែលអាចការពារពីការប្រែប្រួលអាកាសធាតុផ្សេងៗ។
- លំនៅឋានដែលមានទំហំសមរម្យ មានន័យថាមានមនុស្សរស់នៅមិនលើសពីចំនួនបីនាក់នៅក្នុងបន្ទប់រួមតែមួយ។
- ងាយស្រួលទទួលបាន ទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងក្នុងតម្លៃសមរម្យ។
- ទទួលបានបង្គន់អនាម័យឯកជន ឬសាធារណៈគ្រប់គ្រាន់ដែលអាចប្រើប្រាស់បានតាមចំនួនមនុស្សសមស្រប។
- មានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីដែលការពារពីការបណ្តេញចេញដោយបង្ខំ។[៤]

និយមន័យនេះ ដូចគ្នានឹងនិយមន័យដែលត្រូវបានប្រើនៅក្នុងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ហើយស្ទើរតែដូចគ្នានឹងនិយមន័យនៃការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ ដែរ។ នេះអនុញ្ញាតឱ្យរបាយការណ៍នេះ វាយតម្លៃប្រកបដោយទំនុកចិត្តអំពីនិន្នាការដែលទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងកំពុងប្រឈមមុខក្នុងអំឡុងពេលនេះ។ ទោះជាយ៉ាងណាក៏ដោយ និយមន័យនេះអាចបត់បែនបាន ហើយទីតាំងលំនៅឋានមួយចំនួនដែលត្រូវបានចាត់ទុកថាជាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងពីមុនអាចនឹងត្រូវលុបចេញ ប្រសិនបើអ្នកស្រាវជ្រាវ និងអង្គការសមាគមធាងត្នោតយល់ថា ទីតាំងលំនៅឋានក្រីក្រទាំងនេះ លែងស្របតាមលក្ខណៈវិនិច្ឆ័យដែលត្រូវចាត់ទុកថាជាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងទៀត។

## ក្រមសីលធម៌នៃការស្រាវជ្រាវ

អង្គការសមាគមធាងត្នោតធ្វើការយ៉ាងជិតស្និទ្ធជាមួយទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ និងបានបង្កើតទំនាក់ទំនងយ៉ាងច្រើនជាមួយសមាជិកសហគមន៍ទាំងនោះ។ ដើម្បីធានាថា ការប្រមូលទិន្នន័យប្រព្រឹត្តទៅដោយមិនលម្អៀង និងបានអនុវត្តប្រកបដោយក្រមសីលធម៌នៅក្នុងការស្រាវជ្រាវនេះ គោលការណ៍នៃការសម្ភាសត្រូវបានពន្យល់ដល់អ្នកចូលរួមការស្ទង់មតិគ្រប់រូបដូចខាងក្រោម៖

- ការចូលរួមដោយស្ម័គ្រចិត្ត
- រក្សាការសម្ងាត់
- អនាមិកភាព
- ប្រាប់ពីគោលបំណង និងលទ្ធផលនៃការស្រាវជ្រាវ
- ធានាជូនអ្នកចូលរួមថា ព័ត៌មានដែលពួកគេបានចែករំលែកនឹងត្រូវបាន ប្រើប្រាស់សម្រាប់តែគោលបំណងសិក្សាស្រាវជ្រាវ និងសម្រាប់ការតស៊ូមតិប៉ុណ្ណោះ។
- ការយល់ព្រម ដោយមានព័ត៌មានគ្រប់គ្រាន់ មានន័យថាអ្នកចុះប្រមូលទិន្នន័យត្រូវសុំការយល់ព្រមជាពាក្យសម្តីពីអ្នកចូលរួមមុនពេលចាប់ផ្តើមការស្ទង់មតិ និងមិនត្រូវសម្ភាសឡើយ ប្រសិនបើ អ្នកចូលរួមមិនផ្តល់ការយល់ព្រមជាមុន។

[៤] ការបន្ថែមថ្មីនេះ ដែលអនុញ្ញាតឱ្យចាត់ថ្នាក់ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងស្របតាមនិយមន័យរបស់ UN Habitat នៃតំបន់មិនរៀបរយ ត្រូវបានប្រើប្រាស់ក្នុងអំឡុងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ដែលមានន័យថា លំនៅឋានរបស់ពួកគេជារឿយៗត្រូវបានសាងសង់ពីសម្ភារៈល្អប្រសើរជាងមុន (ឧទាហរណ៍ ឥដ្ឋ ស៊ីម៉ងត៍ ផ្ទុយពីឈើ ដីឥដ្ឋ ដែកអេតចាយ) ប៉ុន្តែកន្លែងរស់នៅពួកគេនៅតែងាយរងគ្រោះចំពោះការបណ្តេញចេញដោយបង្ខំដដែល ដោយសារពួកគេមិនបានទទួលឯកសារផ្លូវច្បាប់ដែលផ្តល់សិទ្ធិកាន់កាប់ដល់ពួកគេ។

## ការត្រួតពិនិត្យគុណភាព

ប្រធានក្រុមអ្នកស្រាវជ្រាវបានចុះសង្កេតការងាររបស់អ្នកប្រមូលទិន្នន័យ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកចូលរួមក្នុងអំឡុងពេលសម្ភាស ដើម្បីធានាគុណភាពនៃការសម្ភាស។ ទិន្នន័យត្រូវបានត្រួតពិនិត្យជាក់ស្តែង នៅពេលបញ្ចូលទិន្នន័យទាំងនោះ ហើយប្រធានក្រុមអ្នកស្រាវជ្រាវបានធ្វើការយ៉ាងជិតដិតជាមួយអ្នកសម្ភាស ដើម្បីធានាថាចម្លើយត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ ហើយអ្នកចូលរួមយល់ពីសំណួរ។

## ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះបានទទួលពីប្រភពផ្សេងៗជាច្រើន រួមមានរបាយការណ៍អង្គការសង្គមស៊ីវិល របាយការណ៍រាជរដ្ឋាភិបាល ឯកសារស្រាវជ្រាវ អត្ថបទសារព័ត៌មាន និងការបោះពុម្ពផ្សាយនានាដែលអាចរកបាន។ លើសពីនេះទៀត ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អង្គការសមាគមធាងត្នោត ត្រូវបានប្រើជាញឹកញាប់ ដើម្បីបញ្ជាក់អះអាងពីលទ្ធផលរកឃើញនៃរបាយការណ៍នេះ។

## ទិសាលភាព និងដែនកំណត់

### ទីតាំងលំនៅឋានក្រីក្រដែលមិនបានដាក់បញ្ចូល

ទីតាំងលំនៅឋានមួយចំនួន ដែលស្របតាមនិយមន័យដែលត្រូវចាត់ទុកថា ជាលំនៅឋានក្រីក្រក្នុងទីក្រុង អាចមិនត្រូវបានបញ្ចូលនៅក្នុងការស្រាវជ្រាវនេះ។ ដូចបានកត់សម្គាល់ខាងលើ វិធីសាស្ត្រស្រាវជ្រាវធ្វើឱ្យកត្តានេះទំនងជាកើតឡើងបាន ដោយសារក្រុមអ្នកស្រាវជ្រាវមិនអាចចុះទៅបានគ្រប់តំបន់នៃរាជធានីភ្នំពេញ តាមចិរវេលាដែលបានកំណត់សម្រាប់ការស្រាវជ្រាវនេះ។

### ការយល់ដឹងរបស់អ្នកចូលរួមផ្តល់បទសម្ភាស

ទិន្នន័យការស្ទង់មតិនេះ ពឹងផ្អែកស្ទើរតែទាំងស្រុងលើការយល់ដឹងរបស់អ្នកផ្តល់បទសម្ភាស អំពីបញ្ហានានា ពាក់ព័ន្ធនឹងទីតាំងលំនៅឋានរបស់ពួកគេ រួមទាំងការប៉ាន់ស្មានពីចំនួនខ្នងផ្ទះ និងចំនួនគ្រួសារ និងការយល់ដឹងអំពីសុវត្ថិភាព ក្នុងការកាន់កាប់ដីធ្លីស្របច្បាប់។ ទិន្នន័យដែលទទួលបានត្រូវពិនិត្យផ្ទៀងផ្ទាត់ធៀបជាមួយនឹងទិន្នន័យគោល របស់អង្គការសមាគមធាងត្នោត ឬធៀបនឹងប្រភពទិន្នន័យសាធារណៈផ្សេងទៀត។ អ្នកប្រមូលទិន្នន័យ បានពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានមួយចំនួនដែលបានផ្តល់ឱ្យដោយការរាប់ខ្នងផ្ទះ ការសង្កេតហេដ្ឋារចនាសម្ព័ន្ធ ឬការពិនិត្យឯកសារច្បាប់ផងដែរ។ ប៉ុន្តែ ក្នុងករណីដែលអង្គការសមាគមធាងត្នោតគ្មានទិន្នន័យ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ ឬមិនបានសម្ភាស តំណាងទីតាំងលំនៅឋានក្រីក្រផ្សេងទៀត ព័ត៌មានដែលផ្តល់ដោយអ្នកផ្តល់បទសម្ភាសត្រូវចាត់ទុកជាព័ត៌មានពិតដោយគ្មានការសង្ស័យ។

## ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជន

រាជធានីភ្នំពេញបានបែងចែកជា ១៤ ខណ្ឌ។ ខណ្ឌចំនួន ៥ បានចាត់ទុកថាជាខណ្ឌខាងក្នុងរាជធានីភ្នំពេញ មានដូចជាខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌទួលគោក និងខណ្ឌ៧មករា។ ខណ្ឌទាំង៥ នេះមានចម្ងាយប្រមាណជា ៣,៥គីឡូម៉ែត្រ ពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ហើយមានផ្ទៃដី ៤០គីឡូម៉ែត្រការ៉េ ឬស្មើនឹង៤% នៃផ្ទៃដីរាជធានីភ្នំពេញទាំងមូល។ ខណ្ឌ៩ ផ្សេងទៀតចាត់ទុកថាជាខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញដែល មានចម្ងាយប្រហែល ២០គីឡូម៉ែត្រ ពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ។

ការសិក្សាមុនៗនៅក្នុងរាជធានីភ្នំពេញ បានរកឃើញថាទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញមានលទ្ធភាពខុសៗគ្នារវាងខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅក្នុងការទទួលបានសេវាសាធារណៈរបស់រដ្ឋាភិបាល ដូចជាទឹកស្អាត និងអគ្គិសនី។ លើសពីនេះទៀត ការសិក្សានេះក៏បានបង្ហាញផងដែរថា ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនទំនងជាមានការកើនឡើងនៅខណ្ឌខាងក្រៅ និងថយចុះ ឬបាត់នៅខណ្ឌខាងក្នុងមួយផ្នែកដោយសារសេវាកាន់តែប្រសើរឡើងនៅខណ្ឌខាងក្នុង និងមួយផ្នែកដោយសារគម្រោងតាំងទីលំនៅឋានថ្មី ដែលបានបណ្តេញសហគមន៍ចេញពីខណ្ឌខាងក្នុងទៅខណ្ឌខាងក្រៅ។ ជាលទ្ធផល ទិន្នន័យត្រូវបានបែងចែកតាមប្រភេទនៅក្នុងលទ្ធផលរកឃើញទាំងមូល ដើម្បីបង្ហាញពីភាពខុសគ្នាដោយផ្អែកលើការបែងចែកខណ្ឌខាងក្នុងធៀបនឹងខណ្ឌខាងក្រៅ ដែលការបែងចែកនេះមានទំហំធំដុំគួរឱ្យកត់សម្គាល់។

ជំពូកនេះបង្ហាញពីទិន្នន័យសំខាន់ៗស្តីពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ ដែលត្រូវបានកំណត់ដោយការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣។ ក្នុងករណីដែលអាចធ្វើបានទិន្នន័យត្រូវបានបកស្រាយដើម្បីបង្ហាញការប្រែប្រួលពីការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ឬការស្រាវជ្រាវមុន។



# ៣. លទ្ធផលរកឃើញសំខាន់ៗ

## ការថយចុះចំនួនទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ

ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ បានរកឃើញថាមានទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចំនួន ២៧៧ទីតាំងលំនៅឋានក្រីក្រ។ ការស្រាវជ្រាវថ្មីនេះ បានរកឃើញទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចំនួន ១៩១ ទីតាំងលំនៅឋានក្រីក្រ ដែលបន្តធ្លាក់ចុះនៃចំនួនទីតាំងលំនៅឋានក្រីក្រ ក្នុងរាជធានី ដែលបានរកឃើញដោយអង្គការសមាគមធាងត្នោត នៅក្នុងការស្រាវជ្រាវពីមុនៗមក។ តារាងខាងក្រោម កត់ត្រាពីទម្រង់នៃការធ្លាក់ចុះនៃចំនួនទីតាំងលំនៅឋានក្រីក្រជាទូទៅចាប់តាំងពីឆ្នាំ១៩៩៧ លើកលែងតែ ឆ្នាំ២០០៣ ដែលជាពេលវេលាតែមួយគត់ ដែលអ្នកស្រាវជ្រាវបានកត់ត្រាការកើនឡើងនៃចំនួនទីតាំងលំនៅឋានក្រីក្រពីរបាយការណ៍មុន។ ការស្រាវជ្រាវឆ្នាំ២០០៣ ក៏បង្ហាញពីចំនួនខ្ពស់បំផុតនៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងដែលត្រូវបានកត់ត្រាផងដែរ ពោលគឺបានឈានដល់ ៥៦៩ទីតាំងលំនៅឋានក្រីក្រ។ តាមការប្រៀបធៀបការស្រាវជ្រាវឆ្នាំ២០២៣ បានរកឃើញតិចជាងពាក់កណ្តាលនៃទីតាំងលំនៅឋានក្រីក្រទាំងនោះ ដែលបច្ចុប្បន្នជាទីតាំងលំនៅឋានក្រីក្រក្នុងរាជធានី។ សរុបមក ទីតាំងលំនៅឋានចំនួន៨៦ ដែលមានក្នុងអំឡុងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ត្រូវបានដកចេញពីការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣ ដោយហេតុផលផ្សេងៗ។ ទីតាំងលំនៅឋានភាគច្រើនត្រូវបានដកចេញគឺដោយសារទីតាំងទាំងនោះមិនបានបំពេញលក្ខណៈវិនិច្ឆ័យដែលត្រូវចាត់ទុកជាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង។

ការសិក្សាស្រាវជ្រាវលើកមុន និងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣ បានចងក្រងឯកសារអំពីទីតាំងលំនៅឋានក្រីក្រ ដែលបានធ្វើការកែលម្អជាច្រើនគួរឱ្យកត់សម្គាល់ ឬដែលទទួលបានសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ ដែលធ្វើឱ្យក្រុមទីតាំងលំនៅឋានក្រីក្រទាំងនោះ ត្រូវបានដកចេញពីចំណាត់ថ្នាក់ជា ‵ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជន′។ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍មួយចំនួន ក្នុងរាជធានីភ្នំពេញក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ មានន័យថាចំនួននៃទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីបានធ្លាក់ចុះជាបន្តទៀត។ ឧទាហរណ៍៖ ទីតាំងលំនៅឋានក្រីក្រចំនួន ៤២ទីតាំង បានរាយការណ៍ថា ពួកគេបានទទួលប័ណ្ណកម្មសិទ្ធដីធ្លីក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ប៉ុន្តែដោយសារសហគមន៍ជាច្រើនមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធដីធ្លីសម្រាប់ការតាំងទីលំនៅឋានទាំងស្រុង ឬជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬនៅតែស្ថិតក្នុងសភាពជាជនងាយរងគ្រោះដោយសារលំនៅឋានមិនសមរម្យ ទីតាំងលំនៅឋានក្រីក្រជាច្រើននៅតែចាត់ទុកថាជាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងស្របតាមនិយមន័យខាងលើ។

ការថយចុះនៃទីតាំងលំនៅឋានក្រីក្រក្នុងកំណត់ត្រានេះ មិនឆ្លុះបញ្ចាំងតែលទ្ធផលវិជ្ជមានប៉ុណ្ណោះទេ។ អង្គការលើកលែងទោសអន្តរជាតិបានរាយការណ៍ថា ទីតាំងលំនៅឋានចំនួន៩ នៅរាជធានីភ្នំពេញត្រូវបានបណ្តេញចេញក្នុងអំឡុងពេលមានវិបត្តិជំងឺរាតត្បាតជាសកលកូវីដ-១៩ ចាប់ពី ឆ្នាំ២០២០ ដល់ឆ្នាំ២០២២។ ទីតាំងលំនៅឋានមួយចំនួននៃទីតាំងលំនៅឋានទាំងនេះ មិនត្រូវបានរាប់បញ្ចូលក្នុងការស្ទង់មតិក្នុងរាជធានីភ្នំពេញមុនៗទេ ដោយសារពួកគេត្រូវបានរំលង ឬតាំងទីលំនៅក្នុងរាជធានីភ្នំពេញក្រោយឆ្នាំ២០១៧

មានន័យថា អ្នកស្រាវជ្រាវសម្រាប់ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ មិនបានដឹងអំពីទីតាំងលំនៅឋានក្រីក្រទាំងនោះទេ។ ប្រជាជនដែលត្រូវបានបណ្ដេញចេញឱ្យទៅរស់នៅទីតាំងថ្មី ភាគច្រើនពិបាកទាក់ទងសម្ភាសដោយក្រុមអ្នកសិក្សាស្រាវជ្រាវ ដោយសារពួកគាត់ត្រូវរស់នៅបែកខ្ញែកគ្នា ក្នុងនោះមានគ្រួសារខ្លះបានទុកដីចោល ឬលក់ឱ្យអ្នកផ្សេងរួចត្រឡប់មកជួលផ្ទះនៅក្នុងទីក្រុងវិញដើម្បីអាចប្រកបរបរចិញ្ចឹមជីវិត។ ទីតាំងលំនៅឋានក្រីក្រដែលត្រូវបានបណ្ដេញចេញ ឬស្ថិតក្នុងស្ថានភាពលែងក្រ ត្រូវបានចុះក្នុងទិន្នន័យស្ទង់មតិថា 'ត្រូវបានលុបចេញ' ដែលនាំឱ្យមានការធ្លាក់ចុះចំនួនសរុបនៃទីតាំងលំនៅឋានក្រីក្រ។ ប៉ុន្តែក្នុងចំណោមទីតាំងដែលធ្លាក់ចុះមានតែ ៤ប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថាជាទីតាំងដែលត្រូវបានដកចេញដោយការបណ្ដេញចេញ។

សហគមន៍ផ្សេងទៀតក៏មិនត្រូវបានបញ្ចូលនៅក្នុងការស្ទង់មតិរាជធានីភ្នំពេញ ឆ្នាំ២០១៧ដែរ។ សហគមន៍ក្រីក្រទាំងនេះភាគច្រើនកើតឡើងពីកត្តាសេដ្ឋកិច្ច ឬកត្តាអាកាសធាតុ និងការធ្វើចំណាកស្រុកមកទីក្រុងភ្នំពេញ។ យ៉ាងតិចសហគមន៍មួយ ដែលត្រូវបានបណ្ដេញចេញ និងមិនត្រូវបានកត់ត្រានៅក្នុងការស្រាវជ្រាវនេះ បានធ្វើចំណាកស្រុកមករាជធានីភ្នំពេញ ដើម្បីគេចវេសពីបំណុលមីក្រូហិរញ្ញវត្ថុ។

ជារួម អង្គការសមាគមធាងត្នោតមិនអាចបញ្ជាក់ឱ្យប្រាកដថា ការថយចុះជាបន្តបន្ទាប់នៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងនឹងអាចកើតឡើងនៅពេលអនាគតឡើយ។ ការកើនឡើង ឬថយចុះនៅពេលអនាគតអាស្រ័យលើកត្តាមួយចំនួន ដូចជាទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការបណ្ដេញចេញ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី កត្តាសេដ្ឋកិច្ចដែលជំរុញការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង និងកត្តាផ្សេងទៀត ដូចជាការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិជាដើម។ គួរកត់សម្គាល់ថា ទោះបីមានការកើនឡើងទីតាំងលំនៅឋានក្រីក្រ ដែលរាយការណ៍ថាបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីក៏ដោយក៏ចំនួននៃទីតាំងលំនៅឋានក្រីក្រនៅទីក្រុងសរុបមិនមានការថយចុះច្រើនដែរ ដូចជាអ្វីដែលបានបង្ហាញនៅក្នុងការស្រាវជ្រាវទាំងពីរលើកកន្លងមក។



**តារាងទី១៖** ចំនួនទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចន្លោះឆ្នាំ១៩៩៧ និងឆ្នាំ២០២៣[៥]

| ខណ្ឌខាងក្នុង | ១៩៩៧ | ២០០៣ | ២០០៩ | ២០១៣ | ២០១៧ | ២០២៣ |
|---|---|---|---|---|---|---|
| ៧មករា | ៥៧ | ៥៨ | ៣០ | ១៧ | ៩ | ៧ |
| ចំការមន | ៦៧ | ៦៨ | ២៩ | ២៥ | ១៩ | ៦ |
| បឹងកេងកង | - | - | - | - | - | ៣ |
| ដូនពេញ | ៧២ | ៨១ | ៣២ | ១៧ | ១៣ | ៩ |
| ទួលគោក | ៦០ | ៤៨ | ៣៨ | ២១ | ១៥ | ១១ |
| **សរុប** | **២៥៦** | **២៥៥** | **១២៩** | **៨០** | **៥៦** | **៣៦** |
| | **៧១%** | **៦០%** | **៣៦%** | **២៥%** | **២០%** | **១៩%** |
| **ខណ្ឌខាងក្រៅ** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** | **២០២៣** |
| ច្បារអំពៅ | - | - | - | - | ៣៦ | ២៧ |
| ជ្រោយចង្វារ | - | - | - | - | ១៣ | ៨ |
| ដង្កោ | ១៦ | ១៤១ | ៥៤ | ២៥ | ២៣ | ១៩ |
| មានជ័យ | ៤៦ | ៩៤ | ៩៣ | ៨៩ | ៤១ | ២៩ |
| ពោធិ៍សែនជ័យ | - | - | - | ២៨ | ១៩ | ១៣ |
| កំបូល | - | - | - | - | - | ១ |
| ឫស្សីកែវ | ៦១ | ៧៩ | ៩៦ | ៨៧ | ៥២ | ៣៤ |
| សែនសុខ | - | - | ៣៨ | ៣១ | ២៧ | ១២ |
| ព្រែកព្នៅ | - | - | - | - | ១០ | ១២ |
| សរុប | ១០៧ | ១៧៣ | ២២៧ | ២៣៥ | ២២១ | ១៥៥ |
| | ២៩% | ៤០% | ៦៤% | ៧៥% | ៨០% | ៨១% |
| សរុបរួម | ១៩៩៧ | ២០០៣ | ២០០៩ | ២០១៣ | ២០១៧ | ២០២៣ |
| | ៣៧៩ | ៥៦៩ | ៤១០ | ៣៤០ | ២៧៧ | ១៩១ |

[៥] នៅឆ្នាំ២០១៩ ខណ្ឌពោធិ៍សែនជ័យ ត្រូវបានបំបែកជា ២ ខណ្ឌ គឺខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល ហើយខណ្ឌចំការមន ត្រូវបានបំបែកជាខណ្ឌចំការមន និងខណ្ឌបឹងកេងកង។

ក្រាហ្វិកទី១៖ សមាមាត្រនៃទីតាំងលំនៅឋាននៅខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅចន្លោះឆ្នាំ១៩៩៧-២០២៣



តារាងទី២៖ ចំនួនគ្រួសារក្រីក្រនៅរាជធានីភ្នំពេញចន្លោះឆ្នាំ១៩៩៧ និងឆ្នាំ២០២៣

| ខណ្ឌខាងក្នុង | ១៩៩៧ | ២០០៣ | ២០០៩ | ២០១៣ | ២០១៧ | ២០២៣ |
|---|---|---|---|---|---|---|
| ៧មករា | ១៧៦២ | ៣៨៧៥ | ១៨៨៤ | ៦១១ | ២៨៣ | ២១៩ |
| ចំការមន | ៦៤៧៩ | ៨៥៧៤ | ២៤២១ | ២២៧០ | ២០៥១ | ៩៧០ |
| បឹងកេងកង | - | - | - | - | - | ៦៣ |
| ដូនពេញ | ២៩៧០ | ៧១៨៨ | ២៣៣៧ | ៦១៤ | ១០៥៥ | ៨០២ |
| ទួលគោក | ៣៤១១ | ៤៥៤០ | ៤៩២០ | ២២៨៨ | ១៤៩៤ | ២២៨១ |
| សរុប | ១៤៦២២ | ២៤១៧៧ | ១១៥៦២ | ៥៧៨៣ | ៤៨៨៣ | ៤៣៣៥ |
| | ៤៨% | ៣៩% | ២៩% | ១៧% | ១៩% | ២២% |
| ខណ្ឌខាងក្រៅ | ១៩៩៧ | ២០០៣ | ២០០៩ | ២០១៣ | ២០១៧ | ២០២៣ |
| ច្បារអំពៅ | - | - | - | - | ២៣៩២ | ២៥៩៤ |
| ជ្រោយចង្វារ | - | - | - | - | ៨៦៧ | ៥៦១ |
| ដង្កោ | ៩០៣ | ១៩៦៩០ | ៧២៤២ | ៣៩៧៦ | ៤២៧០ | ១២៨៤ |
| មានជ័យ | ៦៦៥៦ | ៥៣៨២ | ៩០០២ | ៧០១៧ | ២២៧៤ | ៣១៥១ |
| ពោធិ៍សែនជ័យ | - | - | - | ៤៥៥១ | ២៩១៥ | ១៧៥៤ |
| កំបូល | - | - | - | - | - | ៣០ |
| ឬស្សីកែវ | - | - | - | - | ៥២០០ | ៣៤៦៥ |
| សែនសុខ | ៧៩៦៩ | ១៣០០០ | ៨៤៨២ | ៦០២៣ | ១៧២៧ | ១០៦១ |
| ព្រែកព្នៅ | - | - | ៤២៦០ | ៦២៥៥ | ១៦៧៩ | ១៣០៤ |
| សរុប | ១៥៥២៨ | ៣៨០៧២ | ២៨៩៨៦ | ២៧៨២២ | ២១៣២៤ | ១៥២០៤ |
| | ៥២% | ៦១% | ៧១% | ៨៣% | ៨១% | ៧៨% |
| សរុបរួម | ១៩៩៧ | ២០០៣ | ២០០៩ | ២០១៣ | ២០១៧ | ២០២៣ |
| | ៣០១៥០ | ៦២២៤៩ | ៤០៥៤៨ | ៣៣៦០៥ | ២៦២០៧ | ១៩៥៣៩ |

## លក្ខណៈរួមនៃទីតាំងលំនៅឋានក្រីក្រ

ដូចគ្នាជាមួយការស្ទង់មតិ ក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៧ ទីតាំងលំនៅឋានក្រីក្រភាគច្រើនត្រូវបានបង្កើតឡើងនៅចន្លោះឆ្នាំ១៩៧៨ និង ឆ្នាំ២០០១។ មានទីតាំងលំនៅឋានតិចតួច (១៤%) ដែលត្រូវបានបង្កើតឡើងក្រោយឆ្នាំ២០០២ ដែលអាចបង្ហាញថា ទីតាំងលំនៅឋានទាំងនេះត្រូវបានបណ្តេញចេញ ហើយបន្ទាប់មកបានតាំងទីលំនៅថ្មីដូចបានលើកឡើង ដោយការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ ឬអាចបង្ហាញថា លំនាំនៃចំណាកស្រុកពីជនបទទៅទីក្រុងកំពុងប្រែប្រួល ដោយសារការស្រាវជ្រាវនេះ រកឃើញភស្តុតាងនៃសហគមន៍ថ្មីៗដែលត្រូវបានបង្កើតឡើងចាប់តាំងពីការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ ២០១៧។

អនុសាសន៍គន្លឹះសម្រាប់អនាគតគឺ៖ គួរធ្វើការសិក្សាពីតួនាទីនៃចំណាកស្រុកពីជនបទទៅទីក្រុង ដើម្បីធានាថា រាជធានីភ្នំពេញក៏ដូចជាទីប្រជុំជនផ្សេងទៀតនៅជុំវិញប្រទេសកម្ពុជា ត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលតាំងទីលំនៅឋានថ្មី។ ភស្តុតាងដែលប្រមូលបានដោយអង្គការសមាគមធាងត្នោត បង្ហាញថា ចំណាកស្រុកពីជនបទទៅទីក្រុងអាចកើតមានឡើង ដោយសារតែការបាត់បង់ការងារ ដែលបង្កឡើងដោយជំងឺរាតត្បាតជាសកលកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ គ្រួសារចង់បានជីវភាពធូរធារនៅក្នុងទីក្រុង និងការកើនឡើងនៃបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បង្ខំឱ្យលក់ដីធ្លី និងចំណាកស្រុក ដើម្បីសេដ្ឋកិច្ច។

ក្រាហ្វិកទី២៖ ទីតាំងលំនៅឋានក្រីក្រត្រូវបានបង្កើតនៅក្នុងឆ្នាំ




ទីតាំងលំនៅឋានក្រីក្រ នៅរាជធានីភ្នំពេញភាគច្រើនមានប្រជាពលរដ្ឋរស់នៅតិចជាង ២០០គ្រួសារ ដែលអាចបង្ហាញថា ទោះបីជាទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ មានការថយចុះនៃចំនួនសរុបក៏ដោយក៏ចំនួនគ្រួសារ ក្នុងមួយទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ កំពុងកើនឡើង។ ចំនួនគ្រួសារជាមធ្យមក្នុងមួយទីតាំងលំនៅឋានក្រីក្រ មានចំនួន ១០២គ្រួសារ ដែលក្នុងចំណោមទាំងអស់ ទីតាំងលំនៅឋានក្រីក្រ គ្រួសារដែលធំជាងគេមានចំនួនគ្រួសាររហូតដល់ទៅ ១ ១៤៦គ្រួសារ។ តួលេខនេះមានសង្គតិភាពជាមួយកំណើនប្រជាជន ដែលបានប៉ាន់ប្រមាណ ប៉ុន្តែមិនមានភាពច្បាស់លាស់ថា តើអាជ្ញាធរ មានផែនការដោះស្រាយយ៉ាងណានៅឡើយទេ ចំពោះការកើនឡើងទីតាំងលំនៅឋានក្រីក្រ ដែលពួកគេអះអាងថា ជាទីតាំងលំនៅឋាន "ខុសច្បាប់" (លក្ខណៈភាពខុសច្បាប់នៃទីតាំងលំនៅឋានក្រីក្រមួយចំនួនត្រូវបានសិក្សាបន្ថែមខាងក្រោម)។ មានភាពច្បាស់លាស់ដែរថា ទីតាំងលំនៅឋានជាច្រើនមិនមានលំហរូបវន្តសម្រាប់ការពង្រីក (លើកលែងតែអាចសាងសង់ឡើងលើបាន) មានន័យថាគ្រួសារជាច្រើនកំពុងនៅផ្ទះតែមួយជាមួយគ្នា និងរស់នៅក្នុងស្ថានភាពចង្អៀត។

## ក្រុមជនជាតិភាគតិច

ជនជាតិខ្មែរជាក្រុមដែលមានចំនួនច្រើនជាងគេ (ជាង៩០%) នៃទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ ក្រុមជនជាតិភាគតិចផ្សេងទៀតរួមមាន ជនជាតិវៀតណាម ចិន ចាម និងកម្ពុជាក្រោម (ជនជាតិខ្មែរដែលមានដើមកំណើតនៅវៀតណាម)។

ក្រាហ្វិកទី៣៖ ក្រុមជនជាតិសំខាន់ៗ





## លទ្ធផលគេឃើញសំខាន់ៗ

- មានការថយចុះ ជាបន្តបន្ទាប់នៃទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញពី ២៧៧ ទីតាំង ក្នុងឆ្នាំ២០១៧ ដល់ ១៩១ ទីតាំងលំនៅឋានក្រីក្រក្នុងឆ្នាំ២០២៣។
- មានការកើនឡើងយ៉ាងឆាប់រហ័សនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លីដែលបានរាយការណ៍ថាសហគមន៍បានទទួល ក៏ប៉ុន្តែភាគច្រើននៃរបាយការណ៍នេះមិនត្រូវបានបញ្ជាក់ ហើយនៅតែមិនទាន់មានភាពមិនច្បាស់លាស់នៅឡើយថា តើសហគមន៍ទាំងមូលបានទទួលប័ណ្ណកម្មសិទ្ធិមែនឬក៏អត់ដែរ។ សហគមន៍ចំនួន១៩ទីតាំង បានរាយការណ៍ពួកគេបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីតាំងពីឆ្នាំ២០១៧។
- អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងព័ត៌មានរបស់អង្គការសមាគមធាងត្នោតបង្ហាញថា ទីតាំងលំនៅឋានថ្មីត្រូវបានគេរកឃើញ ប៉ុន្តែក្រោយមកទីតាំងមួយចំនួនត្រូវបានគេបណ្តេញចេញតាំងពីឆ្នាំ២០១៧។ នេះគឺជាចំណុចថ្មីមួយដែលបង្ហាញថា ត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមអំពីសមត្ថភាព និងគោលនយោបាយរបស់រាជធានីភ្នំពេញសម្រាប់ចាត់ចែងការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។

## ការកាន់កាប់ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការតាំងទីលំនៅថ្មី

### ប្រភេទដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លី

*ប្រភេទដីធ្លី*

នៅប្រទេសកម្ពុជាដីត្រូវបានបែងចែកជាបីប្រភេទសំខាន់ៗ ដូចតាមការកំណត់ដោយច្បាប់ភូមិបាលឆ្នាំ២០០១៖[៦]

- ដីរដ្ឋ៖ ដីរដ្ឋត្រូវបានចែកជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដីសាធារណៈរបស់រដ្ឋ គឺជាដីដែលត្រូវបានកាន់កាប់ដោយរដ្ឋសម្រាប់ជាផលប្រយោជន៍ និងបម្រើសាធារណជនទូទៅប្រើប្រាស់ ដែលមានដូចជា ផ្លូវថ្នល់ ផ្លូវដែក ទីតាំងបេតិកភណ្ឌ សាលារៀន មន្ទីរពេទ្យ និងអគាររដ្ឋបាលជាដើម។ ដីឯកជនរបស់រដ្ឋគឺជាដី ដែលមិនមែនសម្រាប់បម្រើប្រយោជន៍សាធារណៈទេ។ ដីឯកជនរបស់រដ្ឋអាចជួល ឬលក់បាន ប៉ុន្តែដីសាធារណៈរបស់រដ្ឋមិនអាចជាកម្មសិទ្ធិរបស់នរណាម្នាក់ក្រៅពីរដ្ឋទេ។
- ដីឯកជន៖ ជាដីធ្លីដែលជាកម្មសិទ្ធិ ឬកាន់កាប់ដោយភាគីឯកជន។
- ដីសមូហភាព៖ ដីធ្លីដែលជាកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច (តាមសហគមន៍) ឬវត្តអារាមនានា។

*ប្រភេទប័ណ្ណកម្មសិទ្ធិដីធ្លី*

ទាក់ទងទៅនឹងភាពជាម្ចាស់កម្មសិទ្ធិនៃដីឯកជនភ័ស្តុតាងនៃកម្មសិទ្ធិដែលមិនអាចប្រកែកបានគឺជា

[៦] សម្រាប់ការពិភាក្សាលម្អិតបន្ថែមអំពីប្រភេទដី សូមមើល៖ អង្គការសមាគមធាងត្នោត (ឆ្នាំ២០១៣)។ គោលនយោបាយសម្រាប់ជនក្រីក្រ?៖ ភ្នំពេញ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងសារាចរលេខ ០៣. ភ្នំពេញ៖ អង្គការសមាគមធាងត្នោត។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលជាទូទៅគេហៅថា "ប្លង់រឹង"។



- ប្លង់រឹង៖ គឺជាវិញ្ញាបនបត្រផ្លូវការបញ្ជាក់ពីសិទ្ធិជាម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជី និងចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ វាជាប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីដែលទទួលស្គាល់ដោយថ្នាក់ជាតិ និងមិនអាចប្រកែកបានកម្មសិទ្ធិភាព និងផ្តល់សិទ្ធិដល់ម្ចាស់កម្មសិទ្ធិក្នុងការចាត់ចែងផ្សេងៗទៅលើដីនោះ។

ឯកសារផ្សេងទៀតដែលគេប្រើជាទូទៅដើម្បីបង្ហាញពីកម្មសិទ្ធិអាចទទួលបានតាមរយៈអាជ្ញាធរ និងមានប្រយោជន៍ក្នុងការផ្តល់ភ័ស្តុតាងនៃភាពជាម្ចាស់ប៉ុន្តែមិនរឹងមាំដូចប្លង់រឹងទេ។

- ប្លង់ទន់៖ ជាប្រភេទឯកសារ ដែលបានមកពីឯកសារផ្ទេរដីធ្លី (កិច្ចសន្យាដែលមានសាក្សីជាផ្លូវការ លិខិតទទួល និងឯកសារផ្សេងៗទៀត) ដែលបានចុះបញ្ជីនៅថ្នាក់សង្កាត់ និងខណ្ឌ។ ប្លង់ទន់នេះ គឺជាការទទួលស្គាល់នូវសិទ្ធិរបស់ម្ចាស់ក្នុងការកាន់កាប់ដីធ្លី ប៉ុន្តែវាមិនសំខាន់ដូចប្លង់រឹង។

ស្ថានភាពផ្នែកច្បាប់នៃក្បាលដីជាច្រើននៅក្នុងរាជធានីភ្នំពេញ នៅមិនទាន់បានចុះបញ្ជីជាផ្លូវការ និងចេញប័ណ្ណសម្គាល់កម្មសិទ្ធិដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់នៅឡើយទេ។ ប្រជាពលរដ្ឋជាច្រើនបានរស់នៅក្នុងផ្ទះរបស់ខ្លួន ដោយមានការអនុញ្ញាតជាក់ស្តែងពីអាជ្ញាធរមូលដ្ឋាន ឬមានកិច្ចសន្យាទិញ-លក់ដី ប៉ុន្តែពួកគេមិនមានប័ណ្ណសម្គាល់ជាម្ចាស់ដីទេ។ ករណីនេះបង្កឱ្យមានបញ្ហាប្រឈមសំខាន់ៗសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមទីតាំងលំនៅក្រីក្រក្នុងរាជធានី ដោយសារពួកគេជាញឹកញាប់តាំងទីលំនៅក្រីក្រនៅជិតដីដែលគេចាត់ទុកថាជាដីរដ្ឋ។ ជាលទ្ធផល អំណះអំណាងដែលគេប្រើច្រើនបំផុតក្នុងការបណ្តេញចេញប្រជាពលរដ្ឋពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីគឺថា៖ ប្រជាពលរដ្ឋកាន់កាប់ដីរដ្ឋ[៧] ជាអំណះអំណាងមួយដែលមិនអនុវត្តចំពោះអ្នកមានប្លង់រឹង។ រដ្ឋាភិបាលបានខកខានក្នុងការបញ្ចប់កម្មវិធីចេញប័ណ្ណកម្មសិទ្ធិដីធ្លីជាច្រើនទសវត្សរ៍មកហើយ ប៉ុន្តែភ័ស្តុតាងមួយចំនួនបង្ហាញថា ទីតាំងលំនៅឋានមួយចំនួនបច្ចុប្បន្នកំពុងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ ទោះបីជាយ៉ាងនេះក្តី ត្រូវអោយមានព័ត៌មានបន្ថែមអំពីបញ្ហានេះ។

[៧] អង្គការសមាគមធាងត្នោត៖ ការបណ្តេញចេញ និងការផ្លាស់ប្តូរលំនៅឋាន ឆ្នាំ២០១៩។

# សិទ្ធិទទួលបានលំនៅឋានសមរម្យ – សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី

## *ប្រភេទដីធ្លី*

ជាងមួយភាគបីនៃប្រជាពលរដ្ឋនៅទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានរាយការណ៍ថា ពួកគេរស់នៅលើដីរដ្ឋ។ សារៈសំខាន់នៃលទ្ធផលរកឃើញនេះគឺថាការរស់នៅលើដីរដ្ឋទំនងជាមានន័យថា ប្រជាពលរដ្ឋមិនអាចទទួលបានប័ណ្ណកម្មសិទ្ធិលើដីរបស់ខ្លួន ឬយ៉ាងហោចណាស់ក៏មិនងាយស្រួលក្នុងការទទួលបានដែរ។ ប្រវត្តិនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញក៏បង្ហាញបែបនេះដែរ។ អ្វីដែលគួរឱ្យព្រួយបារម្ភគឺ៖ សហគមន៍ភាគច្រើនមិនមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរ ដើម្បីបង្ហាញថាពួកគេបានសង់លំនៅឋានលើដីរដ្ឋទេ។



ក្រាហ្វិកទី៤៖ ប្រភេទដីដែលបានសង់លំនៅឋាន




## *ប្លង់កម្មសិទ្ធិ*

ភាគច្រើន (៦៩%) នៃប្រជាពលរដ្ឋនៅលើទីតាំងលំនៅឋានក្រីក្រក្នុងរាជធានី បាននិយាយថា ពួកគេមិនមានឯកសារជាលាយលក្ខណ៍អក្សរបញ្ជាក់ពីស្ថានភាពដីធ្លីរបស់ពួកគេទេ។ នេះស្របគ្នា ជាមួយទីតាំងលំនៅឋានក្រីក្រចំនួន ៦៣% ដែលមិនបានឆ្លងកាត់ដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធត្រូវបានអនុវត្តដោយអាជ្ញាធរកម្ពុជា អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ដីនៅទូទាំងប្រទេស។ វឌ្ឍនភាពដ៏យឺតយ៉ាវនេះបានធ្វើឱ្យទីតាំងលំនៅឋានក្រីក្រនៅរាជធានីជាច្រើនគ្មានឯកសារបង្ហាញស្ថានភាពដីច្បាស់លាស់។ ជាលទ្ធផល អសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងការភ័យខ្លាចចំពោះ ការបណ្តេញចេញត្រូវបានរកឃើញក្នុងចំណោមសហគមន៍ក្រីក្រ ជិតពីរភាគបី នៃរាជធានីភ្នំពេញ ដែលមិនមានឯកសារជាលាយលក្ខណ៍អក្សរ។ ប្រជាពលរដ្ឋ នៅទីតាំងលំនៅឋានក្រីក្រជាច្រើនជឿជាក់ថាការផាត់ចេញសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធជាភស្តុតាងដែលបង្ហាញថា ពួកគេនឹងទទួលរងការបណ្តេញចេញនៅពេលអនាគត។ ការពិតដែលថាទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ តែងតែត្រូវបានគេបដិសេធក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ឬទំនងជាការរើសអើង។ លើសពីនេះទៀត ការបដិសេធមិនផ្តល់ព័ត៌មានដល់សហគមន៍ក្នុងលក្ខខណ្ឌច្បាស់លាស់អំពីស្ថានភាពកម្មសិទ្ធិដីធ្លីរបស់ពួកគេគឺជាការបដិសេធសិទ្ធិរបស់ពួកគេក្នុងការទទួលបានលំនៅឋានសមរម្យដែលមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ជាសមាសភាគដ៏សំខាន់។[៨]

ក្នុងចំណោមទីតាំងលំនៅឋានក្រីក្រ ដែលបានឆ្លងកាត់ដំណើរការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ ទីតាំងលំនៅឋានក្រីក្រ ចំនួន៥៨ បាននិយាយថា ពួកគេបានទទួលប្លង់កម្មសិទ្ធិ ហើយពេលនេះត្រូវបានទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិដីស្របច្បាប់។ នេះគឺជាការកើនឡើងនៃទីតាំងលំនៅឋានប្រហែលជា ១៩ ទីតាំងថ្មីបន្ថែមចាប់តាំងពីការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧។

ការអង្កេត និងស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៥ បានរកឃើញថាទីតាំងលំនៅឋានក្រីក្រចំនួន៩១.៧% នៅក្នុងរាជធានីភ្នំពេញត្រូវបានគ្រប់គ្រងដោយម្ចាស់កម្មសិទ្ធិ។[៩] នេះជាភស្តុតាងដែលបង្ហាញថា ប្រទេសកម្ពុជាមានគម្លាតរវាងទីតាំងលំនៅឋានក្រីក្ររបស់ប្រជាជនទូទៅ និងទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ដោយទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងទំនងជា បានឆ្លងកាត់ដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធតិចតួចបំផុត។ វាត្រូវបានមើល ឃើញថារាជរដ្ឋាភិបាលរើសអើងចំពោះសហគមន៍ក្រីក្រក្នុងទីក្រុង ដោយមិនបានផ្តល់អាទិភាពដល់ពួកគេនៅក្នុងដំណើរការនេះ ហើយទុកឱ្យពួកគេស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។

---

[៨] សូមមើលគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) នៃអង្គការសហប្រជាជាតិ មតិទូទៅលេខ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា១១.១) ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧។

[៩] អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៥ វិទ្យាស្ថានជាតិស្ថិតិ (កម្ពុជា)។ បានដកស្រង់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ ពី៖ https://www.nis.gov.kh/index.php/ebout/general-information/14-cses/12-cambodia-socio-economic-survey-reports

ក្រាហ្វិកទី៥៖ ទីតាំងលំនៅឋានដែលបានចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ




## ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី

ប្រជាជនក្រីក្រ នៅរាជធានីភ្នំពេញរស់នៅក្នុងទីតាំងចំនួន ៥៦ទីតាំង (២៩%) បានរាយការណ៍ថាកំពុងប្រឈមនឹងការបណ្តេញចេញ និងឬរងសម្ពាធឱ្យផ្លាស់ប្តូរទីលំនៅ។ យោងតាមគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់អង្គការសហប្រជាជាតិ៖ "ការបណ្តេញចេញដោយបង្ខំ គឺជាការដកចេញជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នផ្ទុយពីឆន្ទៈរបស់បុគ្គលគ្រួសារ និងឬសហគមន៍ពីលំនៅឋាន និងឬដីធ្លីដែលពួកគេកាន់កាប់ ដោយគ្មានការផ្តល់ និងដោយមិនទទួលបានកិច្ចគាំពារផ្លូវច្បាប់ ឬកិច្ចការពារផ្សេងទៀត ក្នុងទម្រង់សមស្រប"។

សម្ពាធឱ្យផ្លាស់ប្តូរទីលំនៅ ដោយគ្មានការផ្តល់កិច្ចការពារផ្លូវច្បាប់ក្នុងទម្រង់សមស្របគឺជាការប៉ុនប៉ងបណ្តេញចេញដោយបង្ខំ ហើយរដ្ឋាភិបាលត្រូវតែផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរអំពីស្ថានភាពសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍ ជាជាងផ្សព្វផ្សាយពាក្យចចាមអារ៉ាម និងបណ្តោយឱ្យពួកគេរស់នៅដោយគ្មានសុវត្ថិភាពចំពោះសិទ្ធិកាន់កាប់ដីធ្លី។ សហគមន៍អន្តរជាតិទទួលស្គាល់ការបណ្តេញចេញដោយបង្ខំថាជាការរំលោភសិទ្ធិមនុស្សយ៉ាងកំរោល។ ក្នុងនាមជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត ដែលហាមឃាត់ការបណ្តេញចេញ ដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សដែលពាក់ព័ន្ធកម្ពុជាមានកាតព្វកិច្ចបញ្ឈប់ការបណ្តេញចេញដោយបង្ខំ និងការពារប្រជាពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ។

លទ្ធផលរកឃើញនេះបង្ហាញពីការកើនឡើងនៃការបណ្តេញចេញដែលអាចកើតឡើង ដោយសារការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ គ្រាន់តែបានរកឃើញថា ទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីចំនួន ៤១ (១៥%) បានរាយការណ៍ថា ពួកគេប្រឈមការបណ្តេញចេញ និងឬរងសម្ពាធឱ្យផ្លាស់ប្តូរទីលំនៅ។ ការកើនឡើងនៃការគំរាមកំហែងបណ្តេញចេញ និងសម្ពាធឱ្យទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីផ្លាស់ប្តូរទីលំនៅ មានការពាក់ព័ន្ធជាមួយគោលនយោបាយរបស់រដ្ឋាភិបាល ដែលផ្តល់អាទិភាពលើការផ្តល់ដីសាធារណៈឱ្យក្រុមហ៊ុន និងបុគ្គលឯកជន។[១០] មានការស្រាវជ្រាវសំខាន់ៗ ដែលភាគច្រើនបានធ្វើឡើងដោយអង្គការសមាគមធាងត្នោត ហើយត្រូវបានផ្សព្វផ្សាយដោយសារព័ត៌មានសំឡេងប្រជាធិបតេយ្យ ដែលបច្ចុប្បន្នត្រូវបានដកអាជ្ញាបណ្ណ បង្ហាញពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ដីសាធារណៈឱ្យក្រុមហ៊ុន និងបុគ្គលឯកជនក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្រផ្តល់ដីសាធារណៈ សម្រាប់ប្រជាពលរដ្ឋរស់នៅទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញណាស់។

អ្នកជំនាញផ្សេងទៀតលើកឡើងថា ការខកខានក្នុងការអនុវត្តដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងទីតាំងលំនៅឋានក្រីក្រក្នុងរាជធានី មានគោលបំណងច្បាស់លាស់ និងកើតឡើងស្របពេលដែលរដ្ឋាភិបាលបានដាក់ស្លាកដីនោះថាជាដីរដ្ឋ ដោយមិន

[១០] សូមមើល របាយការណ៍ស្តីពីការពិត និងតួលេខ#៤០៖ បឹងចុងក្រោយ ឆ្នាំ២០១៩ របស់អង្គការសមាគមធាងត្នោត។

បានឆ្លងកាត់ដំណើរការត្រួតពិនិត្យ និងពិគ្រោះយោបល់ត្រឹមត្រូវ។[១១]អ្នកជំនាញនិយាយថា នៅពេលដែលដីនេះ ត្រូវបានចាត់ថ្នាក់ជាដីរដ្ឋវាកាន់តែងាយស្រួលនៅក្រោមច្បាប់កម្ពុជា ក្នុងការបណ្តេញពលរដ្ឋចេញពីទីតាំងលំនៅឋាន បើទោះជាកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជាតម្រូវឱ្យមានការត្រួតពិនិត្យតាមផ្លូវច្បាប់លើដំណើរការនេះក៏ដោយ។[១២]

សម្ពាធឱ្យផ្លាស់ប្តូរលំនៅឋាន និងការគំរាមកំហែងបណ្តេញចេញត្រូវបានរាយការណ៍ដោយពលរដ្ឋនៅទីតាំងលំនៅឋានក្រីក្រ ប៉ុន្តែកម្រមានការកត់ត្រា និងផ្តល់ជាទម្រង់ជាលាយលក្ខណ៍អក្សរអំពីការគំរាមកំហែងទាំងនោះណាស់។ មានតែក្រោមមួយភាគបួននៃទីតាំងលំនៅឋានក្រីក្រទាំងនោះប៉ុណ្ណោះ ដែលប្រឈមនឹងការបណ្តេញចេញ ឬការតាំងទីលំនៅថ្មីបានបង្ហាញថាពួកគេបានទទួលព័ត៌មាននេះតាមរយៈមធ្យោបាយទំនាក់ទំនងផ្លូវការ (កិច្ចប្រជុំផ្លូវការ ឬការជូនដំណឹងផ្លូវការ)។

ទោះយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់អាចផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរឡើយ បើទោះបីជា ពលរដ្ឋអ្នកតាំងទីលំនៅឋានមួយចំនួនបានលើកឡើងពីការទទួលបានការជូនដំណឹងក៏ដោយ។ ព័ត៌មានភាគច្រើនត្រូវបានទទួលក្នុងទម្រង់មិនលាយលក្ខណ៍អក្សរ តាមរយៈការជូនដំណឹងដោយផ្ទាល់មាត់ពីអាជ្ញាធរ ឬនៅក្នុងកិច្ចប្រជុំ (៨%) ឬតាមរយៈពាក្យចចាមអារ៉ាម (៩%)។ ការជូនដំណឹងអំពីការបណ្តេញចេញតាមភាសានិយាយជំនួសឱ្យការសរសេរបានធ្វើឱ្យអ្នកផ្តល់បទសម្ភាសរឹតតែពិបាក ក្នុងការផ្តល់ព័ត៌មានលម្អិតថា តើហេតុអ្វីបានជាពួកគេត្រូវបានបណ្តេញចេញ និងថាតើដំណើរការនោះមានលក្ខណៈដូចម្តេច។ អ្នកផ្តល់បទសម្ភាសបានរាយការណ៍ពីអារម្មណ៍ភិតភ័យ និងអារម្មណ៍តានតឹងដោយសារខ្វះខាតព័ត៌មានច្បាស់លាស់។ ការជូនដំណឹងជាលាយ-លក្ខណ៍អក្សរអំពីការបណ្តេញចេញ ត្រូវបានតម្រូវដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[១៣]

ក្រាហ្វិកទី៦៖ មូលហេតុនៃការបណ្តេញចេញ និង
ការតាំងទីលំនៅថ្មី




## សារាចរលេខ ០៣

ក្នុងករណីដែលទីតាំងលំនៅឋានស្ថិត នៅលើដីសាធារណៈរបស់រដ្ឋ ច្បាប់ភូមិបាល (ឆ្នាំ២០០១) បញ្ជាក់យ៉ាងច្បាស់ថា ពួកគេទំនងជាមិនអាចទទួលបានកម្មសិទ្ធិស្របច្បាប់លើដីនោះ។[១៤] មាត្រាផ្សេងទៀតដាក់ទោសពិន័យលើការកាន់កាប់ដីរដ្ឋ។[១៥] គេកម្រប្រើប្រាស់ច្បាប់ភូមិបាល ដើម្បីផ្តន្ទាទោសអ្នកតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ប៉ុន្តែគេតែងតែបដិសេធសិទ្ធិរបស់ពលរដ្ឋទាំងនេះក្នុងការទទួលបានលំនៅឋានសមរម្យ ដោយសម្អាងលើមាត្រា ១៥ នៃច្បាប់នេះ។

[១១] បទសម្ភាសជាមួយអ្នកជំនាញ រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០២៣។
[១២] ដូចខាងលើ។
[១៣] សូមមើលគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) នៃអង្គការសហប្រជាជាតិ មតិទូទៅលេខ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា១១.១) ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧។
[១៤] មាត្រា១៥ និង១៦។
[១៥] មាត្រា១៩ ច្បាប់ភូមិបាល (ឆ្នាំ២០០១)។

ប្រជាជនទីតាំងលំនៅឋានក្រីក្រជាច្រើន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះទាមទារថាតំបន់ដែលពួកគេរស់នៅជាកម្មសិទ្ធិរបស់ពួកគេតាំងពីយូរមកហើយ រាជរដ្ឋាភិបាលបានព្យាយាមបង្កើតសេចក្តីណែនាំក្នុងការដោះស្រាយស្ថានភាពនេះ ដោយមិនរំលោភសិទ្ធិរបស់អ្នកតាំងទីលំនៅក្នុងការទទួលបានលំនៅឋានសមរម្យ ឬដោយមិនអនុវត្តការបណ្តេញចេញដោយបង្ខំ។ សេចក្តីណែនាំនេះ គឺសារាចរណែនាំស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និង ទីប្រជុំជន (ឆ្នាំ២០១០) ("សារាចរលេខ ០៣")។[១៦]

សារាចរលេខ ០៣ ផ្តល់ព័ត៌មានដល់អាជ្ញាធរដើម្បីដោះស្រាយ "ការទន្ទ្រានកាន់កាប់ដោយខុសច្បាប់" ដោយទីតាំងលំនៅឋាន នៅលើដីសាធារណៈរបស់រដ្ឋ។ ស្របពេលដំណាលគ្នានេះ សារាចរនេះ ក៏មានបញ្ញត្តិដែលអនុញ្ញាតឱ្យមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងការអភិវឌ្ឍនៅនឹងកន្លែងផងដែរ ប៉ុន្តែវាក៏បញ្ជាក់ឡើងវិញផងដែរពីការសន្មតថា ទីតាំងលំនៅឋានគឺ "ខុសច្បាប់" និង "បណ្តោះអាសន្ន" ដោយមិនផ្តល់យន្តការណាមួយដើម្បីបញ្ជាក់ថា តើនេះពិត ឬមិនពិតឡើយ។[១៧] ការណ៍ដែលរាជរដ្ឋាភិបាលមិនបានបញ្ជាក់អំពីស្ថានភាពដីធ្លីនៃទីតាំងលំនៅឋានក្រីក្រជាច្រើនដែលចូលរួមក្នុងការស្រាវជ្រាវនេះ មានន័យថាពួកគេមិនបានដឹងថាពួកគេពិតជាទន្ទ្រានកាន់កាប់ដីធ្លីដោយខុសច្បាប់ឬអត់ឡើយ។

សារាចរលេខ ០៣ មិនមានទម្ងន់ភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ទេ[១៨] មានន័យថា សារាចរនេះមិនមានតួនាទីជាការការពារទប់ទល់នឹងការបណ្តេញចេញដោយបង្ខំឡើយ។ ដោយសារសារាចរនេះ ខ្វះទម្ងន់អាជ្ញាធរមិនសូវបានអើពើ មិនបានដឹងអំពីវា ឬជ្រើសរើសមិនប្រើប្រាស់។

ប្រជាពលរដ្ឋភាគច្រើន (៧៨%)នៃទីតាំងលំនៅឋានក្រីក្របានរាយការណ៍ថា ពួកគេមិនដែលបានឮពីសារាចរលេខ ០៣ ទេ[១៩] ដែលសឱ្យឃើញថាអាជ្ញាធរមិនផ្តល់អាទិភាពលើសេចក្តីណែនាំនោះ ហើយផ្ទុយទៅវិញ ពួកគេជ្រើសរើសយកជម្រើសផ្សេង នៅពេលរកឃើញថា ទីតាំងលំនៅឋានស្ថិតនៅលើដីរដ្ឋ។[២០] កត្តានេះ ធ្វើឱ្យប៉ះពាល់ដល់សារៈសំខាន់នៃសារាចរលេខ០៣ និងបង្ហាញពីភាពខុសគ្នារវាងគោលនយោបាយ និងការអនុវត្តក្នុងអភិបាលកិច្ចតំបន់ក្រីក្រក្នុងទីក្រុងនៅកម្ពុជា។

---

[១៦] ចេញផ្សាយក្នុងឆ្នាំ ២០១០ សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន បានផ្តល់ក្របខណ្ឌសម្រាប់ដោះស្រាយបញ្ហានៃទីតាំងលំនៅឋានខុសច្បាប់កាប់កាប់លើដីរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ភាពមិនច្បាស់លាស់ទាក់ទងនឹងទីតាំងរបស់ខ្លួនក្នុងច្បាប់ភូមិបាល និងរបៀបអនុវត្តច្បាប់ជាក់ស្តែងបានកាត់បន្ថយប្រសិទ្ធភាពរបស់ច្បាប់នេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។
[១៧] ដូចខាងលើ – សូមមើលចំណងជើងនៃសារាចរលេខ០៣។
[១៨] ដូចខាងលើ។
[១៩] ដូចខាងលើ។
[២០] អង្គការសមាគមធាងត្នោត ការស្ទង់មតិក្នុងរាជធានីភ្នំពេញ(ឆ្នាំ២០១៧)។

# ច្បាប់សិទ្ធិមនុស្ស

ទោះបីជាទីតាំងលំនៅឋានក្រីក្រជាច្រើនស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ ដូចជាបឹង ឬផ្លូវរថភ្លើងក៏ដោយ នេះមិនមែនមានន័យថា រាជរដ្ឋាភិបាលអាចបណ្តេញប្រជាពលរដ្ឋចេញ ឬដាក់ពួកគេនៅក្នុងស្ថានភាពដែលទាល់ច្រកគ្មានជម្រើសផ្សេងក្រៅពីការបង្ខំខ្លួនឯងឱ្យចាកចេញ (ដូចជា បង្ហូរទឹកឱ្យជន់លិចផ្ទះរបស់ពួកគេ ដើម្បីបង្ខំឱ្យពួកគេចាកចេញ)។

តាមច្បាប់សិទ្ធិមនុស្ស ការបណ្តេញចេញដោយបង្ខំគឺជាការដកចេញជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នផ្ទុយពីឆន្ទៈរបស់បុគ្គល គ្រួសារ និងឬសហគមន៍ពីលំនៅឋាន និងឬដីធ្លី ដែលពួកគេកាន់កាប់ ដោយគ្មានការផ្តល់ និងដោយមិនទទួលបានកិច្ចគាំពារផ្លូវច្បាប់ ឬកិច្ចការពារផ្សេងទៀត ក្នុងទម្រង់សមស្រប។[២១] នៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) និងសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងទៀត កម្ពុជាមានកាតព្វកិច្ចគោរព ការពារ និងបំពេញបន្ថែមសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ និងទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ។

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ (គណៈកម្មាធិការអង្គការសហប្រជាជាតិ) បានសង្កត់ធ្ងន់នៅក្នុងយោបល់ទូទៅចំណុចទី៧ របស់ខ្លួនថា ការបណ្តេញចេញអាចត្រូវបានអនុវត្ត នៅពេលដែលជម្រើសផ្សេងសម្រាប់ការបណ្តេញចេញត្រូវបានពិនិត្យ។[២២]

គោលការណ៍ និងការណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅផ្អែកលើការអភិវឌ្ឍ (គោលការណ៍ជាមូលដ្ឋាន) ចែងថា៖ ដំណើរការរៀបចំផែនការ និងអភិវឌ្ឍទីក្រុង ឬជនបទគួរមានការចូលរួមពីបុគ្គលគ្រប់រូបដែលអាចរងផលប៉ះពាល់ ហើយគួរបញ្ចូលដូចតទៅនេះ (ក) សេចក្តីជូនដំណឹងសមស្របដល់បុគ្គលគ្រប់រូបដែលអាចរងផលប៉ះពាល់ថា ការបណ្តេញចេញកំពុងត្រូវបានពិចារណា ហើយនិងមានវេទិកាសាធារណៈអំពីផែនការ និងជម្រើសដែលបានស្នើ។ (ខ) ការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដោយអាជ្ញាធរនូវព័ត៌មានពាក់ព័ន្ធជាមុន រួមទាំងកំណត់ត្រាដីធ្លី និងផែនការតាំងទីលំនៅថ្មីដែលបានស្នើឡើងគ្រប់ជ្រុងជ្រោយ ដែលលើកឡើងជាក់លាក់អំពីកិច្ចប្រឹងប្រែងដើម្បីការពារក្រុមងាយរងគ្រោះ។ (គ) ចិរវេលាសមហេតុផលសម្រាប់ការពិនិត្យជាសាធារណៈ ការផ្តល់យោបល់ និងឬការជំទាស់លើផែនការដែលបានស្នើ។ (ឃ) ឱកាស និងកិច្ចប្រឹងប្រែងជួយសម្រួលដល់ការផ្តល់យោបល់ផ្នែកច្បាប់ បច្ចេកទេស និងយោបល់ផ្សេងទៀត ដល់បុគ្គលដែលរងផលប៉ះពាល់ អំពីសិទ្ធិ និងជម្រើសរបស់ពួកគេ និង(ង) រៀបចំសវនាការសាធារណៈ




[២១] សូមមើលគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) នៃអង្គការសហប្រជាជាតិ មតិទូទៅលេខ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា១១.១) ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧។ កថាខ័ណ្ឌ៣។
[២២] សូមមើលគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) នៃអង្គការសហប្រជាជាតិ មតិទូទៅលេខ៧៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ (មាត្រា១១.១) ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧។ កថាខណ្ឌ១០-១៧។

ដែលផ្តល់ឱកាសដល់បុគ្គលដែលរងផលប៉ះពាល់ និងអ្នកតស៊ូមតិ ដើម្បីជំទាស់នឹងសេចក្តីសម្រេចលើការបណ្តេញចេញ និងឬបង្ហាញសំណើជាជម្រើស និងដើម្បីលើកឡើងពីតម្រូវការ និងអាទិភាពនៃការអភិវឌ្ឍ"។[២៣]

ជាលទ្ធផល ទីតាំងលំនៅឋានក្រីក្រ ក្នុងទីក្រុងដែលកាន់កាប់ដីសាធារណៈរបស់រដ្ឋ ត្រូវតែទទួលបានការពិគ្រោះយោបល់ ការទទួលបានព័ត៌មានច្បាស់លាស់អំពីស្ថានភាពនៃសិទ្ធិកាន់កាប់ដីធ្លី និងត្រូវបណ្តេញចេញតែក្នុងករណី ដែលការបណ្តេញចេញជាជម្រើសចុងក្រោយប៉ុណ្ណោះ ហើយតែក្នុងករណីដែលការបណ្តេញចេញប្រព្រឹត្តទៅស្របតាមច្បាប់សិទ្ធិមនុស្ស និងរួមបញ្ចូលសំណង និងការផ្លាស់ប្តូរទីលំនៅថ្មីទៅកាន់ទីតាំងដែលត្រូវបានរៀបចំយ៉ាងពេញលេញសម្រាប់ពួកគេ និងមិនធ្វើឱ្យពួកគេប្រឈមគ្រោះថ្នាក់ចំពោះការរំលោភសិទ្ធិមនុស្សបន្ថែមទៀតប៉ុណ្ណោះ។ ការបរាជ័យរបស់ប្រទេសកម្ពុជាក្នុងការអនុវត្តកិច្ចការជាច្រើននៃកិច្ចការទាំងនេះ នៅពេលបច្ចុប្បន្ន ជាពិសេស ការខកខានមិនបានផ្តល់ព័ត៌មានច្បាស់លាស់អំពីសុវត្ថិភាពកាន់កាប់ដីធ្លីដល់ទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ ពិតជាធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង។



[២៣] បណ្តាញសិទ្ធិលំនៅឋាន និងដីធ្លី (HLRN) គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅដោយផ្អែកលើការអភិវឌ្ឍន៍ (គោលការណ៍ជាមូលដ្ឋាន) ឆ្នាំ ២០០៧ ឧបសម្ព័ន្ធទី១ សម្រាប់អង្គការសហប្រជាជាតិ។ ឯកសារ, NHRC/4/18, កថាខណ្ឌ៣៧។

## លទ្ធផលរកឃើញសំខាន់ៗ

- ជាងមួយភាគបីនៃទីតាំងលំនៅឋានទាំងអស់ ទំនងជាស្ថិតនៅលើដីរដ្ឋ មានន័យថាពួកគេ មានហានិភ័យខ្លាំងចំពោះការបណ្តេញចេញ និងការបណ្តេញចេញដោយបង្ខំ។
- ជិតពីរភាគបី នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ មិនមានឯកសារជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ពីស្ថានភាពដីដែលពួកគេរស់នៅដែលនេះគឺជាភាពខ្វះចន្លោះរបស់រដ្ឋក្នុងការផ្តល់ភាពច្បាស់លាស់ និងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីចំពោះទីតាំងលំនៅឋានក្រីក្រទាំងនេះ។
- ជាងមួយភាគបួននៃទីតាំងលំនៅឋានក្រីក្រទាំងអស់រាយការណ៍ថា ពួកគេកំពុងទទួលរងសម្ពាធពីការបណ្តេញចេញដោយបង្ខំ។
- ទីតាំងលំនៅឋានក្រីក្រយ៉ាងតិច៩ ត្រូវបានបណ្តេញចេញ ដោយបង្ខំក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩ ។

## ស្ថានភាពលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ

ជំពូកនេះ វាយតម្លៃស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាដោយមានការប្រៀបធៀបរវាងខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញ។

## សិទ្ធិទទួលបានលំនៅឋានសមរម្យ – សុវត្ថិភាព សេវា និងរដ្ឋាភិបាល

### *ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋានក្រីក្រ – ភ្លើងបំភ្លឺផ្លូវ*

ទីតាំងលំនៅឋានក្រីក្រ ចំនួន៤៩% ប៉ុណ្ណោះដែលមានភ្លើងបំភ្លឺផ្លូវក្នុងសហគមន៍ដែលដំណើរការ។ លទ្ធផលរកឃើញនេះ បង្ហាញថា អាជ្ញាធរមិនផ្តល់អាទិភាពលើសុវត្ថិភាពនៃទីតាំងលំនៅឋានក្រីក្រឡើយ នៅពេលរៀបចំ និងផ្តល់មូលនិធិសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។ ការស្រាវជ្រាវលើកមុនដែលធ្វើឡើងដោយអង្គការសមាគមធាងត្នោតបង្ហាញថាភ្លើងបំភ្លឺផ្លូវ មានសារៈសំខាន់ក្នុងការផ្តល់ទីសុវត្ថិភាពដល់ស្ត្រីនៅពេលធ្វើដំណើរនៅក្នុងសហគមន៍របស់ពួកគេ និងធ្វើការនៅពេលយប់។



### *ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋានក្រីក្រ – ប្រព័ន្ធលូរំដោះទឹក*

ប្រព័ន្ធលូរំដោះទឹក នៅតែបន្តជាបញ្ហាសម្រាប់ទីតាំងលំនៅឋានក្រីក្រជាច្រើនក្នុងទីក្រុង។ ទោះយ៉ាងណានេះក្តី មានភ័ស្តុតាងមួយចំនួនបង្ហាញថា បញ្ហាលូរំដោះទឹកកំពុងមានភាពប្រសើរឡើង។ ក្នុងឆ្នាំ២០១៧ ជិតពាក់កណ្តាលនៃទីតាំងលំនៅឋានក្រីក្រនៅទីក្រុងទាំងអស់បានរាយការណ៍ថា មិនមានប្រព័ន្ធលូរំដោះទឹក ខណៈដែលសព្វថ្ងៃនេះមាន ទីតាំងលំនៅឋានក្រីក្រតែមួយភាគបួនប៉ុណ្ណោះ រាយការណ៍ថា មិនមានប្រព័ន្ធលូរំដោះទឹក។ លទ្ធផលរកឃើញនេះបង្ហាញថា ទីតាំងលំនៅឋានក្រីក្រជាច្រើនក្នុងទីក្រុងមានភាពរីកចម្រើនលើប្រព័ន្ធលូរំដោះទឹក។

ក្រាហ្វិកទី៧៖ ប្រភេទនៃប្រព័ន្ធលូរំដោះទឹក






### *ប្រព័ន្ធលូរំដោះទឹក*

ប្រព័ន្ធរំដោះទឹក នៅក្នុងទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងមានភាពប្រសើរឡើង។ បច្ចុប្បន្នទីតាំងលំនៅឋានក្រីក្រចំនួន ១២១ ទីតាំង (ឬ ៦៣%) មានប្រព័ន្ធលូទឹកស្អុយ ឬលូរំដោះទឹកក្រោមដី។ ប៉ុន្តែអ្វីដែលគួរឱ្យព្រួយបារម្ភគឺទីតាំងលំនៅឋានក្រីក្រជាង ២៦% មិនមានប្រព័ន្ធលូរំដោះទឹកក្រោមដី ដែលក្នុងនោះជាង៣៣% មិនទាន់មានប្រព័ន្ធលូរំដោះទឹកដែលអាចសម្គាល់បាននៅឡើយ។

ការស្រាវជ្រាវលើកមុនបានបង្ហាញថា ប្រព័ន្ធរំដោះទឹក និងទឹកជំនន់បានបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង[២៤]។ ពួកគេបានប្រាប់ថា ទឹកជំនន់អាចកើតមានឡើង នៅពេលដែលទីតាំងលំនៅឋានក្រីក្រទាំងនោះមិនមានប្រព័ន្ធរំដោះទឹកគ្រប់គ្រាន់។ ទឹកជំនន់មិនត្រឹមតែបង្ហាញពីហានិភ័យនៃការលង់ទឹក និងការខូចខាតទ្រព្យសម្បត្តិក៏ដូចជាការរឹតបន្តឹងផ្សេងទៀត ដែលបង្កដោយទឹកជំនន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនលទ្ធភាពនៃការរីករាលដាលជំងឺ ក្នុងករណីដែលប្រព័ន្ធលូបង្ហូរទឹកស្អុយទទួលរងការខូចខាត ក្នុងអំឡុងពេលទឹកជំនន់ទៀតផង។

ក្នុងចំណោម ទីតាំងលំនៅឋានក្រីក្រដែលបានរាយការណ៍ថាមានប្រព័ន្ធលូខាងលើ តិចជាង៥០% បានរាយការណ៍ថាប្រព័ន្ធលូរំដោះទឹក "ល្អ"។ អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថា ប្រព័ន្ធលូរំដោះទឹកមិនមានលទ្ធភាពបញ្ចៀសការជន់លិចទឹកក្នុងសហគមន៍របស់ពួកគេបានគ្រប់គ្រាន់ទេ។ អ្នកផ្តល់បទសម្ភាសមួយចំនួនទៀតបានរាយការណ៍ថាមានប្រព័ន្ធលូរំដោះទឹកកាលពីមុនមានលក្ខណៈល្អប្រសើរដែលពេលនេះបានបាក់បែកខូចខាតជាច្រើន។

### *សេវាប្រមូលសំរាម*

ការទទួលបានសេវាប្រមូលសំរាមក៏បានល្អប្រសើរឡើងដែរ។ ទីតាំងលំនៅឋានក្រីក្រចំនួន ៨៥% មានលទ្ធភាពប្រើប្រាស់សេវាប្រមូលសំរាម ដែលជាការកែលម្អប្រសើរលើសពី៤០% ដែលបានបង្ហាញតាមរយៈការស្ទង់មតិ ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧។ ស៊ិនទ្រី (CINTRI) គឺជាក្រុមហ៊ុនប្រមូលសំរាមដ៏លេចធ្លោ (> ៥០%) សម្រាប់ទីតាំងលំនៅឋានដែលមានសេវា។ ទីតាំងលំនៅឋានដែលគ្មានសេវាប្រមូលសំរាមបានរាយការណ៍ថា ពួកគេបានដុតសំរាមចោល ចាក់ចោល ឬកប់ចោល។

តារាងទី០៣៖ វិធីសាស្ត្រគ្រប់គ្រងសំរាម

| វិធីសាស្ត្រគ្រប់គ្រងសំណល់រឹង | ចំនួនទីតាំងលំនៅឋាន | ភាគរយ (%) |
|---|---|---|
| ដុតចោល | ១៧ | ៩.៩០ |
| ចាក់ចោល (គ្មានសេវាប្រមូល) | ៥ | ២.៦១ |
| ចាក់ចោលក្នុងតំបន់ដែលមានសេវាប្រមូលសំណល់រឹង | ៣ | ១.៥៧ |
| កប់ចោល | ១ | ០.៥២ |

### *សេវាទឹកស្អាត*

វាពុំច្បាស់លាស់ថា តើការទទួលបានសេវាទឹកស្អាតពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានភាពប្រសើរឡើងដែរឬទេចាប់ពីឆ្នាំ២០១៧។ ខណៈអ្នកផ្តល់បទសម្ភាសចំនួន ៨៤% បានឱ្យដឹងថាសហគមន៍របស់ខ្លួនបានតភ្ជាប់បណ្តាញទឹកស្អាតជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញរួចហើយ ការស្ទង់មតិឆ្នាំ២០១៧ បង្ហាញថា ចំនួនស្រដៀងគ្នានេះបានតបណ្តាញនេះរួចហើយដែរ។

[២៤] ឧទាហរណ៍ សូមមើលអង្គការសមាគមធាងត្នោត, ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧, អង្គការសមាគមធាងត្នោត, អង្គការលីកាដូ, អង្គការសមធម៌ និងបណ្តាញយុវជនកម្ពុជា, ការបាត់បង់បឹងទំពុន (ឆ្នាំ២០២០) និងអង្គការសមាគមធាងត្នោត, រឿងរ៉ាវរបស់ស្ត្រីក្រីក្រនៅទីក្រុង(ឆ្នាំ២០១៩)។

ក្រាហ្វិកទី៨៖ លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាត ពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




## *សេវាអគ្គិសនី*

ស្រដៀងគ្នានឹងការតភ្ជាប់បណ្ដាញទឹកស្អាតដែរ អ្នកផ្ដល់បទសម្ភាសចំនួន ៩៤% បានរាយការណ៍ថា ទីតាំងលំនៅឋានក្រីក្រ របស់ពួកគេបានតភ្ជាប់បណ្ដាញអគ្គិសនីកម្ពុជា (EDC) ដែលជាអ្នកផ្ដល់អគ្គិសនីរបស់រដ្ឋ។ តួលេខនេះ ខ្ពស់ជាងនឹងបន្តិចចំនួនអ្នកផ្ដល់បទសម្ភាស៩២% ដែលបានរាយការណ៍បែបនេះ នៅក្នុងការស្ទង់មតិឆ្នាំ២០១៧។ អ្នកផ្ដល់បទសម្ភាសចំនួន ៥.៦៧% បានបញ្ជាក់ថា ពួកគេបានតភ្ជាប់បណ្ដាញអគ្គិសនីជាមួយ (EDC) តាមរយៈម្ចាស់ផ្ទះជួល ឬឈ្មួញកណ្ដាល។

ក្រាហ្វិកទី៩៖ លទ្ធភាពទទួលបានសេវាអគ្គិសនី កម្ពុជាសម្រាប់ការប្រើប្រាស់




## កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor)

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់រាជរដ្ឋាភិបាល ដែលមានគោលបំណង ផ្ដល់ការគាំទ្រដល់គ្រួសារក្រីក្រ បន្ទាប់ពីបានកំណត់អត្តសញ្ញាណពួកគេ។ ការទទួលបានសេវាផ្សេងៗដូចជាសេវាថែទាំសុខភាពត្រូវបានរាយការណ៍ថា បានល្អប្រសើរឡើងតាមរយៈសេវានេះ។ មានទីតាំងលំនៅឋានក្រីក្រចំនួនតែ ៣៧% ប៉ុណ្ណោះ បានរាយការណ៍ថា ពួកគេបានទទួលសេវាអត្តសញ្ញាណកម្មសម្រាប់គ្រួសារក្រីក្រទាំងអស់នៅក្នុងសហគមន៍របស់ពួកគេ។ យ៉ាងហោចណាស់តាមរយៈបទពិសោធន៍នេះ បង្ហាញថា គ្រួសារក្រីក្រជាច្រើនកំពុងបាត់បង់ឱកាសទទួលបានអត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ។ ជាវិជ្ជមាន មានបញ្ហាតិចតួច ដែលត្រូវបានរាយការណ៍ដោយអ្នកដែលទទួលបានអត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ ប៉ុន្តែគេត្រូវស្វែងរកទិន្នន័យបន្ថែមទៀត ដើម្បីវាយតម្លៃស្ថានភាពអត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ នៅទូទាំងរាជធានីភ្នំពេញ។ ទិន្នន័យដំបូងហាក់ដូចជាបង្ហាញថា គ្រួសារក្រីក្រជាច្រើនមិនបានទទួលសេវានេះ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្ដល់ប្រាក់កម្ចីដល់ពលរដ្ឋនៅទីតាំងលំនៅឋានក្រីក្រ ដែលជួនកាលបណ្ដាលឱ្យមានវដ្តបំណុល ដែលអ្នកជំពាក់បំណុលត្រូវធ្វើការច្រើនហួសចុកតិច ឬរងទុក្ខវេទនា ដោយសារបន្ទុកបំណុល។ ការស្រាវជ្រាវផ្សេងទៀតបានគូសបញ្ជាក់អំពីលក្ខណៈកេងប្រវ័ញ្ចន៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅទូទាំងប្រទេសកម្ពុជាជាទូទៅ ប៉ុន្តែការស្រាវជ្រាវនេះ បង្ហាញថា បញ្ហាទាំងនេះអាចរីករាលដាលនៅក្នុងទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងផងដែរ។ ការសម្ភាសជាមួយប្រជាពលរដ្ឋនៅទីតាំងលំនៅឋានក្រីក្របង្ហាញថា បញ្ហាបំណុលកើតឡើងនៅក្នុងទីតាំងលំនៅឋានក្រីក្រចំនួន១៤% នៃទីតាំងលំនៅឋានក្រីក្រទាំងអស់។ ទីតាំងលំនៅឋានក្រីក្រចំនួន២៦ បានរាយការណ៍ពីការលក់ផ្ទះដោយសារការខកខានក្នុងការសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។




CINTRI

## ការសន្យារបស់អាជ្ញាធរ

ការស្ទង់មតិនេះ ក៏បានស្វះស្វែងព្យាយាមវាយតម្លៃកម្រិតដែលអាជ្ញាធរឆ្លើយតបទៅនឹងសំណើពីទីតាំងលំនៅឋានក្រីក្រផងដែរ។ ទីតាំងលំនៅឋានក្រីក្រប្រហែល១៤% បានរាយការណ៍ថា ពួកគេទទួលរងនូវការរើសអើង ដោយប្រជាពលរដ្ឋជាច្រើនបាននិយាយថា មូលហេតុនៃការរើសអើង គឺដោយសារតែពួកគេមានជីវភាពក្រីក្រ។ ការស្រាវជ្រាវលើកមុនបានបង្ហាញថា ជាទូទៅទីតាំងលំនៅឋានក្រីក្រនៅទីក្រុងជួបការលំបាកក្នុងការតស៊ូមតិ ដើម្បីឱ្យមានការផ្តល់សេវាកាន់តែប្រសើរដល់សហគមន៍របស់ពួកគេ។ នេះមានទំនាក់ទំនងផ្សាភ្ជាប់ទៅនឹងកត្តាដែលថា ទីតាំងលំនៅឋានក្រីក្រជា "ទីតាំងគ្មានការទាក់ទាញ" ប៉ុន្តែវាក៏ផ្សាភ្ជាប់ទៅនឹងនយោបាយយេនឌ័រផងដែរ ពីព្រោះទីតាំងលំនៅឋានក្រីក្រនៅទីក្រុងជាច្រើនមានស្ត្រីជាអ្នកដឹកនាំ[២៥]។

អាជ្ញាធរពាក់ព័ន្ធ ក៏មិនបានគោរពការសន្យារបស់ខ្លួនចំពោះប្រជាពលរដ្ឋនៅក្នុងទីតាំងលំនៅឋានក្រីក្រចំនួន៨ ក្នុងចំណោមទីតាំងលំនៅឋានក្រីក្រចំនួន៣៤ កន្លែង ដែលពួកគេបានធ្វើការសន្យា។ ជារឿយៗ ការសន្យាទាក់ទងនឹងបញ្ហាជាមូលដ្ឋាន ដូចជាការជួសជុលផ្លូវ ឬការដំឡើងប្រព័ន្ធលូរំដោះទឹកឱ្យប្រសើរឡើង។ អ្នកផ្តល់បទសម្ភាសមួយចំនួនបានលើកឡើងថាអាជ្ញាធរមិនគោរពការសន្យា ដោយសារពួកគេមានផែនការបណ្តេញប្រជាពលរដ្ឋចេញពីទីតាំងលំនៅឋានក្រីក្រនៅពេលអនាគត។

## លទ្ធផលរកឃើញសំខាន់ៗ

- លទ្ធភាពទទួលបានប្រព័ន្ធលូរំដោះទឹកនៅតែខ្វះខាតនៅឡើយនៅក្នុងទីតាំងលំនៅឋានក្រីក្រជាច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋប្រឈមនឹងគ្រោះទឹកជំនន់ និងជំងឺផ្សេងៗ។
- ការតភ្ជាប់បណ្តាញជាមួយសេវារបស់រាជរដ្ឋាភិបាលដូចជាទឹកស្អាត អគ្គិសនី និងការប្រមូលសំរាមមានកម្រិតខ្ពស់ ឬមានការរីកចម្រើនតាំងពីឆ្នាំ២០១៧ មក។
- ទីតាំងលំនៅឋានក្រីក្រជាច្រើន បានរាយការណ៍ថា ការទទួលបានប័ណ្ណសមធម៌នៅតែខ្វះខាត។ ទីតាំងលំនៅឋានក្រីក្រ ដែលបានស្រាវជ្រាវថ្មីៗនេះ រកឃើញថានៅតែមានប្រជាពលរដ្ឋក្រីក្រ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានប័ណ្ណសមធម៌។
- ការជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាបញ្ហាដែលកំពុងបន្ត និងកំពុងកើនឡើង។ ទីតាំងលំនៅឋានក្រីក្រ មួយចំនួនបានរាយការណ៍ថាការលក់ផ្ទះគឺដោយសារតែប្រាក់កម្ចី។ ការណ៍នេះ អង្គការសមាគមធាងត្នោត និងអង្គការសិទ្ធិមនុស្សផ្សេងទៀតជឿថាអាចត្រូវបានផ្តល់ឱ្យដោយធ្វេសប្រហែស។
- ទីតាំងលំនៅឋានក្រីក្រជាច្រើនលើកឡើងថា ពួកគេទទួលរងការរើសអើង ហើយការខ្វះចន្លោះរបស់រាជរដ្ឋាភិបាលមិនគោរពការសន្យារបស់ខ្លួនចំពោះសហគមន៍ បានធ្វើឱ្យបាត់បង់ជំនឿទុកចិត្ត និងបង្កើនអារម្មណ៍រើសអើងកាន់តែច្រើនថែមទៀត។

[២៥] សូមមើលរបាយការណ៍ស្តីពីការពិត និងតួលេខ#៤៧៖ រឿងរ៉ាវរបស់ស្ត្រីក្រីក្រនៅទីក្រុង ឆ្នាំ២០១៩ របស់អង្គការសមាគមធាងត្នោត។



# ៤. សេចក្តីសន្និដ្ឋាន

ចំនួននៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង បានថយចុះចាប់តាំងពីឆ្នាំ២០០៩ ដែលជាការបង្ហាញថា ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងកំពុងទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងការផ្លាស់ប្តូរចេញពីចំណាត់ថ្នាក់នេះ។ ទោះបីជាយ៉ាងនេះក្តី ភ័ស្តុតាងជាក់ស្តែងបង្ហាញពីរឿងរ៉ាវចម្រុះមួយដោយសហគមន៍មួយចំនួនបានផ្លាស់ប្តូរចេញពីចំណាត់ថ្នាក់នេះ ខណៈសហគមន៍មួយចំនួនទៀតបានបាត់ខ្លួនទាំងស្រុងដែលជាញឹកញាប់ដោយសារការបណ្តេញចេញ។ ប៉ុន្តែនៅតែមានសហគមន៍ផ្សេងទៀតបានមកដល់ទីក្រុងភ្នំពេញ ឬត្រូវបានរកឃើញបន្ទាប់ពីត្រូវបានមើលរំលងនៅក្នុងការសិក្សាស្រាវជ្រាវមុនៗ។ ប្រសិនបើពួកគេទើបតែបានមកតាំងទីលំនៅនាពេលថ្មីៗនេះ វាបង្ហាញថាជំងឺរាតត្បាតកូវីដ-១៩ កត្តាសេដ្ឋកិច្ច និងកត្តាផ្សេងទៀតបានបង្ខំឱ្យមានការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។

ទីតាំងលំនៅឋានក្រីក្រ នៅទីក្រុងភ្នំពេញទាំងអស់នៅតែប្រឈមនឹងបញ្ហាជាច្រើន។ ទីតាំងលំនៅឋានក្រីក្រភាគច្រើនមិនមានឯកសារជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ពីស្ថានភាពដីធ្លីរបស់ពួកគេ ហើយមានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មានត្រឹមត្រូវទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី។ ការណ៍នេះធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះ និងងាយទទួលរងការបណ្តេញចេញ ឬការផ្លាស់ប្តូរលំនៅឋាន និងបដិសេធសិទ្ធិរបស់ពួកគេក្នុងការមានលំនៅឋានសមរម្យ ដោយការដកហូតសិទ្ធិរបស់ពួកគេក្នុងការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព។ លើសពីនេះទៀត ស្ទើរតែពាក់កណ្តាលនៃទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងទាំងអស់ស្ថិតនៅជិតផ្ទៃទឹក ដែលមានន័យថា សិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ពួកគេទំនងជាប្រឈមនឹងបញ្ហាផ្លូវច្បាប់ ដោយសារពួកគេអាចរស់នៅលើដីសាធារណៈរបស់រដ្ឋ។

ខណៈកំពុងអនុវត្តជាបន្តនូវកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនបានទៅដល់ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងលឿនតាមតម្រូវការទេ។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាសេវាដ៏សំខាន់ ដែលអាចផ្តល់ជំនួយហិរញ្ញវត្ថុដល់ជនក្រីក្រខ្លាំង ប៉ុន្តែការស្រាវជ្រាវនេះបង្ហាញថា សេវានេះមិនទាន់ទៅដល់អ្នកដែលត្រូវការវានៅឡើយទេ។

ជាចុងក្រោយប្រជាពលរដ្ឋដែលរស់នៅទីតាំងលំនៅឋានក្រីក្រនៅទីក្រុងជាច្រើនកំពុងជំពាក់បំណុលគេ ដែលធ្វើឱ្យពួកគេប្រឈមមុខចំពោះការរំលោភសិទ្ធិមនុស្សដែលអាចកើតមានផ្សេងទៀត ដូចជាការបាត់បង់ដីធ្លី ការគ្មានផ្ទះសម្បែង ការធ្វើចំណាកស្រុកដោយបង្ខំ ការជាប់ចំណងបំណុល ពលកម្មកុមារ និងការកង្វះអាហារហូបចុក។ នេះទាមទារឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម ប៉ុន្តែការបង្ហាញថាគ្រួសារជាច្រើនកំពុងជំពាក់បំណុលគេ គឺជាភ័ស្តុតាងបង្ហាញថា ពួកគេមិនទទួលបានធនធាន ឬឱកាសការងារដែលពួកគេត្រូវការ ដើម្បីរស់នៅប្រកបដោយអត្ថន័យ ដែលអាចជួយពួកគេឱ្យយល់ច្បាស់ពីសិទ្ធិមនុស្សរបស់ខ្លួន និងរំដោះខ្លួនចេញពីភាពក្រីក្របានឡើយ។

# ៥. អនុសាសន៍

## នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រសួងផែនការ

- បន្តពង្រីកកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាពិសេសដោយការបន្តតាមដានលើបញ្ហា ដែលបានរាយការណ៍ទៅនាយកដ្ឋាន និងដោយការបង្កើនកិច្ចប្រឹងប្រែងលើការផ្សព្វផ្សាយ។
- តស៊ូមតិឱ្យបានសកម្មប្រឆាំងនឹងការអនុវត្ត របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធ្វើឱ្យប៉ះពាល់ ដល់គោលបំណងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ពោលគឺតស៊ូមតិដោយផ្អែកលើ មូលដ្ឋានថា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាមធ្យោបាយ ដែលមានសមធម៌ក្នុង ការជួយជនក្រីក្រ ជាងប្រព័ន្ធដែលផ្អែកលើ បំណុល។

## សាលារាជធានីភ្នំពេញ និងក្រសួងផែនការ

- ផ្តល់ និងគាំទ្រការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកាន់តែច្រើនឡើងនៅក្នុង ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង ដោយផ្តោត លើខណ្ឌខាងក្រៅ។ អាទិភាពគួរតែរួមមាន ការធានាថា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានបង្កើតឡើង និងមានដំណើរការ។ ការណ៍នេះអាចធ្វើឡើងដោយធានាថា ធនធានត្រូវបានគ្រប់គ្រាន់ ដើម្បីផ្សព្វផ្សាយ ព័ត៌មានអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងដើម្បីឆ្លើយតបទៅនឹងការប្តឹងអំពីការ រើសអើង ដែលកើតឡើងពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ/រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់

- ប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធប្រកបដោយតម្លាភាព និងដោយមានការសម្របសម្រួល និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី នៅតំបន់ទីប្រជុំជនរហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលនៅតែមាន ការខ្វះចន្លោះច្រើនលើការចុះបញ្ជីដីធ្លី មាន លក្ខណៈប្រព័ន្ធជូនប្រជាពលរដ្ឋ ហើយនេះ អាចជាមូលហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួល បានលំនៅឋានសមរម្យនៃទីតាំងលំនៅឋានក្រីក្រ នៅរាជធានីភ្នំពេញ។ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានកាតព្វកិច្ច លើកតម្កើង និងអនុវត្តការងារ ឈានទៅសម្រេចបានការគោរពសិទ្ធិមនុស្ស ដែលបានចែងក្នុងកតិកាសញ្ញា ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។
- ធ្វើការកែលម្អទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង នៅនឹងកន្លែង (អភិវឌ្ឍន៍នៅនឹងកន្លែង) ជាជម្រើសចម្បង ជំនួសឱ្យការបណ្តេញចេញ និងការសាងសង់លំនៅឋានថ្មី។ ការផ្លាស់ប្តូរលំនៅឋានក្រីក្ររបស់សហគមន៍ទៅខណ្ឌខាងក្រៅ ធ្វើឱ្យសហគមន៍ជួបការលំបាកថែមទៀត ដូចបានបង្ហាញនៅក្នុងរបាយការណ៍នេះ។

**ទីភ្នាក់ងារសហប្រតិបត្តិការនៃប្រទេសអាល្លឺម៉ង់** (GIZ), **ទីភ្នាក់ងារនៃប្រទេសអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ** (AusAID) **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ** (UNDP)

- ត្រូវធានាថាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនធ្លាក់ចូលក្នុងសភាពប្រើប្រាស់លែងកើត គឺកម្មវិធីនេះកំពុងត្រូវបានអនុវត្តមិនបានល្អ និងធ្វើឱ្យបាត់បង់ជំនឿពីអ្នករស់នៅក្នុងទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងដែល អង្គការសមាគមជាងត្នោតបានសម្ភាស។ វាជាកាតព្វកិច្ចរបស់អ្នកផ្តល់មូលនិធិ និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធជាមួយកម្មវិធីនេះ ដើម្បីធានាថាវាអាចអនុវត្ត និងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ហើយការរំលោភសិទ្ធិមនុស្សដែលកើតឡើងពីកម្មវិធីនេះ ត្រូវតែស៊ើបអង្កេត និងចាត់វិធានការជាបន្ទាន់ ហើយដៃគូត្រូវទទួលខុសត្រូវរួមគ្នាក្នុងការដោះស្រាយបញ្ហាទាំងនេះ។ មានភស្តុតាងរួចហើយ ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ ដែលបង្ហាញថា កម្មវិធីអត្តសញ្ញាណគ្រួសារក្រីក្រ មិនត្រូវបានអនុវត្តបានត្រឹមត្រូវឡើយ។
- ធ្វើការដើម្បីជួយសហគមន៍ក្រីក្រក្នុងទីក្រុងឱ្យសម្រេចបានសិទ្ធិកាន់កាប់ដីធ្លី ជីវភាពរស់នៅកាន់តែប្រសើរ និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់ប្រជាពលរដ្ឋដែលមិនមានសិទ្ធិកាន់កាប់ដីធ្លី។
- សម្រាប់សហគមន៍ដែលស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ គួររៀបចំឱ្យមានយុទ្ធនាការសម្រាប់ការប្រើប្រាស់សារាចរណែនាំលេខ ០៣ ដើម្បីឱ្យដំណោះស្រាយអាចធ្វើឡើងតាមរយៈការពិភាក្សា និងការស៊ើបអង្កេតនៅសហគមន៍ និងជាផ្លូវការ។
- ត្រូវធានាថា វិធីសាស្ត្រសហការរួមមួយត្រូវបានគេយកមកប្រើប្រាស់ ជាមួយអាជ្ញាធររាជរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានការដោះស្រាយបញ្ហាដីធ្លីទាំងនោះ។

# ៦. ឧបសម្ព័ន្ធទី១៖ ទម្រង់សម្រាប់ការស្ទង់មតិ

## ការស្ទង់មតិទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ

### ១. ការណែនាំខ្លួនអំពីអង្គការ និងអ្នកសម្ភាស

ក សួស្តី! ខ្ញុំឈ្មោះ........ ហើយខ្ញុំធ្វើការជា........នៅអង្គការសមាគមធាងត្នោត (STT)

ខ អង្គារសមាគមធាងត្នោត គឺជាអង្គការមិនមែនរដ្ឋាភិបាល (NGO) ដែលធ្វើការជាមួយសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ។

គ ការិយាល័យរបស់យើងស្ថិតនៅសង្កាត់ផ្សារដើមថ្កូវ។

ឃ យើងជួយសហគមន៍ក្នុងការគូសផែនទីសហគមន៍ ចាត់អាទិភាពលើតម្រូវការរបស់ពួកគេ និងតស៊ូមតិ ដើម្បីសិទ្ធិរបស់ពួកគេ។

### ២. គោលបំណងនៃការស្ទង់មតិ និងលទ្ធផល

ក បច្ចុប្បន្ន យើងកំពុងស្រាវជ្រាវអំពីស្ថានភាពទូទៅនៃទីតាំងលំនៅឋានក្នុងរាជធានីភ្នំពេញ ដើម្បីគូសបញ្ជាក់ និងធ្វើបច្ចុប្បន្នភាពថា ទីតាំងលំនៅឋានណាខ្លះ ដែលនៅតែត្រូវបានចាត់ទុកថាជាតំបន់ក្រីក្រ និងដើម្បីធ្វើផែនទីទីតាំងលំនៅឋានទាំងនោះបានច្បាស់លាស់ ដើម្បីឱ្យមើលឃើញពីនិន្នាការនៅពេលខាងមុខ។

ខ យើងសង្ឃឹមថានឹងប្រើប្រាស់ព័ត៌មាននេះ ដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់សម្រាប់ទីតាំងលំនៅឋានក្រីក្រ និងការអភិវឌ្ឍ។

គ យើងចង់ដឹងព័ត៌មានទូទៅពីកម្រិតសហគមន៍ ឬទីតាំងលំនៅឋានថា តើស្ថានភាពនៅក្នុងទីតាំងលំនៅឋាន និងសហគមន៍របស់ពួកគេបានផ្លាស់ប្តូរដូចម្តេច។

ឃ យើងនឹងចែករំលែកលទ្ធផលរកឃើញជាមួយសហគមន៍ និងទីតាំងលំនៅឋានដែលពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវ ហើយយើងសង្ឃឹមថា សមាជិកសហគមន៍ និងទីតាំងលំនៅឋាន នឹងអាចប្រើប្រាស់លទ្ធផលរកឃើញទាំងនេះ ដើម្បីជាប្រយោជន៍សម្រាប់សហគមន៍ និងទីតាំងលំនៅឋានរបស់ពួកគេ។

### ៣. តម្លៃដ៏សំខាន់ ដែលត្រូវតែពន្យល់ប្រាប់អ្នកចូលរួមគ្រប់រូប

#### ក. ការចូលរួមដោយស្ម័គ្រចិត្ត

១. អ្នកមិនចាំបាច់ត្រូវតែចូលរួមក្នុងការស្ទង់មតិនេះទេ។

២. អ្នកអាចអញ្ជើញសមាជិកផ្សេងទៀតនៅក្នុងទីតាំងលំនៅឋានឱ្យចូលរួមក្នុងការស្ទង់មតិនេះ។

៣. ប្រសិនបើអ្នកចូលរួម ហើយមានសំណួរណាមួយដែលអ្នកមិនពេញចិត្តក្នុងការឆ្លើយ អ្នក

**ខ. ការយល់ព្រមដោយបានប្រាប់ឱ្យដឹងជាមុន** – បន្ទាប់ពីបានស្តាប់ការពន្យល់អំពីអង្គការ និងគោលបំណងនៃការស្រាវជ្រាវ តើអ្នកមានបំណងចូលរួមក្នុងការស្ទង់មតិនេះឬទេ?

**យើងសូមសម្តែងការដឹងគុណដល់អ្នកចំពោះការយល់ព្រមចូលរួមក្នុងការស្ទង់មតិនេះ។ តើអ្នកមានសំណួរអ្វីចង់សួរយើងដែរឬទេ មុនពេលចាប់ផ្តើមការស្ទង់មតិនេះ?**

QID001: អ្នកសម្ភាសៈ ____________________

QID002: ថ្ងៃខែឆ្នាំសម្ភាសៈ ____/____/២០២២

QID003: លេខសម្គាល់ការស្ទង់មតិៈ _______________

QID004: លេខកូដការស្ទង់មតិឆ្នាំ២០១៧ៈ ___________,លេខកូដសហគមន៍ៈ _________________

QID005: ទីតាំង GPS X: ____________Y: ____________

QID006: ផ្ទៃដីទីតាំងលំនៅឋានៈ ____________ម៉ែត្រការេ

ត្រួតពិនិត្យដោយៈ ___________ ពិនិត្យដោយៈ ______________ថ្ងៃខែឆ្នាំពិនិត្យៈ ____/____/២០២២

## ១. សាវតារ និងព័ត៌មានប្រជាសាស្ត្រ

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ១.១ | ទំនាក់ទំនងរបស់អ្នកសម្ភាស?<br>(អ្នកតំណាង /មេដឹកនាំទីតាំងលំនៅឋានតែប៉ុណ្ណោះ) | ១. ឈ្មោះៈ_____________<br>២. តួនាទីៈ _____________<br>៣. ទូរស័ព្ទៈ_____________ |
| ១.២ | ទំនាក់ទំនងរបស់ប្រធានភូមិ? | ១. ឈ្មោះៈ_____________<br>២. ទូរស័ព្ទៈ_____________ |
| ១.៣ | តើទីតាំងលំនៅឋាននេះមានឈ្មោះទេ? | ១. បាទ/ចាស<br>២. ទេ |
| ១.៤ | តើទីតាំងលំនៅឋាននេះមានឈ្មោះអ្វី? | |
| ១.៥ | ប្រសិនបើគ្មានឈ្មោះ តើវាអាចហៅថាអ្វី? | |
| ១.៦ | តើទីតាំងលំនៅឋាននេះត្រូវបានរៀបចំជាសហគមន៍មួយឬច្រើន? | |
| ១.៧ | តើមានសហគមន៍ប៉ុន្មាន? | ១. បាទ/ចាស<br>២. ទេ |

| | | |
|---|---|---|
| ១.៨ | តើអង្គការក្រៅរដ្ឋាភិបាល ឬសមាគមណាមួយបានជួយដល់សហគមន៍?(បាទ/ចាស/ទេ) | |
| ១.៩ | ទីតាំងបច្ចុប្បន្ន? | ១. ក្រុម____\|_____\|______<br>២. ភូមិ____\|_____\|______<br>៣. សង្កាត់_____________<br>៤. ខណ្ឌ_______________ |
| ១.១០ | តើប្រជាពលរដ្ឋជាលើកដំបូងផ្លាស់ទីមករស់នៅក្នុងទីតាំងនេះនៅពេលណា? | ឆ្នាំ៖_________(ប៉ុណ្ណោះ) |
| ១.១២ | តើមានរចនាសម្ព័ន្ធលំនៅឋានអគារប៉ុន្មានក្នុងទីតាំងលំនៅឋាននេះ? | ប្រហែលជា #: \|__\|__\|__\|__\| |
| ១.១៤ | តើមានប៉ុន្មានគ្រួសារនៅក្នុងទីតាំងលំនៅឋាននេះ? | ប្រហែលជា #: \|__\|__\|__\|__\| |
| ១.១៥ | តើភាគច្រើននៃគ្រួសារនៅទីតាំងលំនៅឋានជាអ្នកជួល ឬជាម្ចាស់? | ១. ម្ចាស់<br>២. អ្នកជួល<br>៣. ម្ចាស់ពាក់កណ្តាល អ្នកជួលពាក់កណ្តាល<br>៤. អត់ដឹង |
| ១.១៦ | តើក្រុមជនជាតិភាគតិចណាមួយ ដែលជាអ្នករស់នៅក្នុងទីតាំងលំនៅឋាននេះ? | ១. ខ្មែរ<br>២. កម្ពុជាក្រោម<br>៣. ចាម<br>៤. ចិន<br>៥. វៀតណាម<br>៦. ផ្សេងៗ |
| ១.១៧ | តើទីតាំងលំនៅឋាននេះជាទីតាំងនៃការផ្លាស់ប្តូរលំនៅឋានថ្មីឬ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |

## ២. ព័ត៌មានអំពីការបណ្តេញចេញ និងសារាចរលេខ ០៣

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ២.១ | តើទីតាំងលំនៅឋានកំពុងជួបប្រទះការបណ្តេញចេញ និង/ឬ សម្ពាធឱ្យផ្លាស់ប្តូរលំនៅឋាន? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង /មិនប្រាកដ |
| ២.២ | តើបញ្ហានេះត្រូវបានទំនាក់ទំនងទៅកាន់ទីតាំងទំលំនៅឋានដោយរបៀបណា? | ១. ការជូនដំណឹងពីការបណ្តេញចេញជាលាយលក្ខណ៍អក្សរផ្លូវការ<br>២. សំណើសុំផ្លាស់ប្តូរលំនៅឋានថ្មីជាលាយលក្ខណ៍អក្សរផ្លូវការ<br>៣. ការជូនដំណឹងពីការបណ្តេញចេញជាពាក្យសម្តី<br>៤. កិច្ចប្រជុំផ្លូវការ<br>៥. សំណើសុំផ្លាស់ប្តូរលំនៅឋានថ្មីជាពាក្យសម្តី<br>៦. តាមរយៈអត្ថបទនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ<br>៧. តាមរយៈពាក្យចចាមអារ៉ាម<br>៨. ផ្សេងៗ |
| ២.៣ | តើបញ្ហានេះត្រូវបានទំនាក់ទំនងមកកាន់សហគមន៍នៅកាលបរិច្ឆេទណាមួយ? | ១. លើកទី ១៖ \ខែ___\ឆ្នាំ___<br>២. លើកទី ២៖ \ខែ___\ឆ្នាំ___<br>៣. លើកទី ៣៖ \ខែ___\ឆ្នាំ___ |
| ២.៤ | តើនរណា/អ្វីជាប្រភពនៃព័ត៌មាននេះ? | ១. អ្នកជិតខាង /មិត្តភក្តិ<br>២. មេភូមិ / អ្នកដឹកនាំសហគមន៍<br>៣. ថ្នាក់សង្កាត់<br>៤. ថ្នាក់ខណ្ឌ<br>៥. ក្រុមហ៊ុន<br>៦. ម្ចាស់លំនៅឋានជួល<br>៧. ផ្សេងៗ |

| | | |
|---|---|---|
| ២.៥ | ប្រសិនបើគ្មានឈ្មោះ តើវាអាចហៅថាអ្វី? | ១. ការសាងសង់អគារ<br>២. ការលុបបឹង (អត់ប្រាកដថាហេតុអ្វី)<br>៣. ការពង្រីកផ្លូវដែលមានស្រាប់<br>៤. ការសាងសង់ស្ពានថ្មី/ផ្លូវថ្មី<br>៥. កែលម្អទីធ្លាបៃតង<br>៦. ការកែលម្អប្រឡាយ<br>៧. ការកែលម្អច្រាំងទន្លេ<br>៨. ការកែលម្អសម្រស់ទីក្រុង<br>៩. ផ្សេងៗ |
| ២.៦ | តើទីតាំងលំនៅឋានបានឮពីសារាចរលេខ ០៣ ឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង /មិនប្រាកដ |
| ២.៧ | តើទីតាំងលំនៅឋានធ្លាប់មានបទពិសោធន៍ផ្ទាល់ណាមួយជាមួយសារាចរលេខ ០៣ ឬទេ? | ១. បាទ/ចាស ធ្លាប់<br>២. ទេ អត់ធ្លាប់ទេ<br>៣. អត់ដឹង /មិនប្រាកដ |
| ២.៨ | តើបទពិសោធន៍ទាំងនោះគឺជាអ្វី?<br>(អាចមានចម្លើយច្រើន)<br>១. កិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន<br>២. អាជ្ញាធរមូលដ្ឋានមកនិយាយ<br>៣. អាជ្ញាធរមូលដ្ឋានប្រមូលព័ត៌មាន<br>៤. ការដាក់បង្ហាញជាសាធារណៈរបស់អាជ្ញាធរមូលដ្ឋាន<br>៥. ការបណ្តុះបណ្តាលជាមួយអង្គការក្រៅរដ្ឋាភិបាល<br>៦. កិច្ចប្រជុំជាមួយអង្គការក្រៅរដ្ឋាភិបាល<br>៧. អង្គការក្រៅរដ្ឋាភិបាលប្រមូលព័ត៌មានផ្សេងៗ | តើបទពិសោធន៍នេះបានកើតឡើងនៅពេលណា?<br><br>\ខែ ____\ឆ្នាំ______ |
| ២.៩ | បើសិនជាបាទ/ចាស តើរឿងនេះកើតឡើងនៅពេលណា? | |

កំណត់សម្គាល់សម្រាប់អ្នកសម្ភាស៖ សូមស្នើសុំច្បាប់ចម្លងនៃសេចក្តីជូនដំណឹងអំពីការបណ្តេញចេញ និងទំនាក់ទំនងផ្សេងទៀតទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លីពីអាជ្ញាធរ

## ៣. សិទ្ធិកាន់កាប់ដីធ្លី

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ៣.១ | តើទីតាំងលំនៅឋានមានទីតាំងនៅលើដីប្រភេទណា? | ១. តាម/លើទន្លេ<br>២. តាម/លើប្រឡាយ<br>៣. តាម/លើស្រះធម្មជាតិ<br>៤. តាម/លើស្រះសិប្បនិម្មិត ឬមនុស្សបង្កើត<br>៥. តាម/លើបឹង<br>៦. តាម/លើផ្លូវ<br>៧. លើដំបូល<br>៨. នៅតាមផ្លូវរថភ្លើង<br>៩. នៅខាងក្នុងឃ្លាំង / រចនាសម្ព័ន្ធផ្សេងទៀត<br>១០. នៅតាមជញ្ជាំង (ឧ. វត្តអារាម សាលារៀន ផ្សារ . ) |
| ៣.២ | តើមាននរណាម្នាក់បានជូនដំណឹងដល់សមាជិកនៃទីតាំងលំនៅឋាន ពីប្រភេទដីដែលពួកគេកំពុងរស់នៅនោះទេ? | ១. បាទ/ចាស – ឯកជនរបស់រដ្ឋ<br>២. បាទ/ចាស – សាធារណៈរបស់រដ្ឋ<br>៣. បាទ/ចាស – ដីឯកជនដែលជាកម្មសិទ្ធិរបស់យើង<br>៤. បាទ/ចាស– ដីឯកជនដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង<br>៥. មិនមានព័ត៌មាន<br>៦. មិនអនុវត្តចំពោះ (អ្នកជួល) |

| | | |
|---|---|---|
| ៣.៣ | ប្រសិនជាមាន តើនរណាបានប្រាប់ទីតាំងលំនៅឋានពីបញ្ហានេះ? | ១. អ្នកជិតខាង / មិត្តភក្តិ<br>២. ប្រធានភូមិ / អ្នកដឹកនាំសហគមន៍<br>៣. ថ្នាក់សង្កាត់<br>៤. ថ្នាក់ខណ្ឌ<br>៥. អាជ្ញាធរដែលធ្វើការចុះបញ្ជីដីធ្លី<br>៦. ម្ចាស់ដី<br>៧. ផ្សេងៗ |
| ៣.៤ | តើទីតាំងលំនៅឋាននេះមានឯកសារជាលាយលក្ខណ៍អក្សរកំណត់ពីស្ថានភាពដីឬទេ? (ប្រសិនបើមាន សូមពិពណ៌នា និងផ្តល់ច្បាប់ចម្លងមួយ) | ១. បាទ/ចាស មាន។ ពិពណ៌នា៖<br>២. ទេ |
| ៣.៥ | តើទីតាំងលំនៅឋាននេះបានឆ្លងកាត់ដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (SLR) ដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.៦ | ប្រសិនបើមាន តើដំណើរការនេះបានកើតឡើងនៅពេលណា? | កាលបរិច្ឆេទចេញប័ណ្ណកម្មសិទ្ធិដីធ្លី៖ \ខែ___\ឆ្នាំ_____ |
| ៣.៧ | តើទីតាំងលំនៅឋានបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.៨ | ប្រសិនបើមាន តើរចនាសម្ព័ន្ធចំនួនប៉ុន្មានបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី? | រចនាសម្ព័ន្ធ #៖ \|__\|__\|__\| |
| ៣.៩ | តើទីតាំងលំនៅឋានបានដាក់ពាក្យស្នើសុំការចុះបញ្ជីជាប្រព័ន្ធ/ប័ណ្ណកម្មសិទ្ធិដីធ្លីដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.១០ | ប្រសិនបើមាន តើការស្នើសុំនេះបានកើតឡើងនៅពេលណា? | កាលបរិច្ឆេទ៖ \ខែ___\ឆ្នាំ_____ |

| | | |
|---|---|---|
| ៣.១១ | ប្រសិនបើមាន តើមានលទ្ធផលអ្វីទេ? | ១. បាទ/ចាស– ត្រូវបានទទួលយក (ប៉ុន្តែមិនទាន់បានអនុវត្ត)<br>២. ទេ – ត្រូវបានបដិសេធ<br>៣. ទេ– គ្មានចម្លើយ |
| ៣.១២ | ប្រសិនបើទីតាំងលំនៅឋានមិនបានឆ្លងកាត់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (SLR) តើតំបន់ដែលនៅជុំវិញទីតាំងលំនៅឋានត្រូវបានចុះបញ្ជីដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង/មិនប្រាកដ |
| ៣.១៣ | តើទីតាំងលំនៅឋានត្រូវបានប្រាប់ថា ទីតាំងលំនៅឋាននេះត្រូវបានដកចេញពីការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ (SLR) ដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង/មិនប្រាកដ |
| ៣.១៤ | តើទីតាំងលំនៅឋាននេះបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.១៥ | ប្រសិនបើមាន តើការស្នើសុំនេះបានកើតឡើងនៅពេលណា? | កាលបរិច្ឆេទ៖ \ខែ___\ឆ្នាំ_____ |
| ៣.១៦ | ប្រសិនបើមាន តើមានលទ្ធផលអ្វីទេ? | ១. បាទ/ចាស– ត្រូវបានទទួលយក និងអនុវត្ត<br>២. បាទ/ចាស– ត្រូវបានទទួលយក មិនទាន់បានអនុវត្ត<br>៣. ទេ – ត្រូវបានបដិសេធ<br>៤. ទេ– មិនមានចម្លើយ |
| ៣.១៧ | ប្រសិនត្រូវបានអនុវត្ត តើមានរចនាសម្ព័ន្ធចំនួនប៉ុន្មានត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី? | រចនាសម្ព័ន្ធ#៖ ___\|___\|__\| |
| ៣.១៨ | តើទីតាំងលំនៅឋានបានស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីបន្ថែមទៀតដែរឬទេ (សារាចរលេខ ០៦)? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.១៩ | ប្រសិនបើមាន តើការស្នើសុំនេះបានកើតឡើងនៅពេលណា? | កាលបរិច្ឆេទ៖ \ថ្ងៃ___\ខែ___\ឆ្នាំ_____ |

| | | |
|---|---|---|
| ៣.២០ | ប្រសិនបើមាន  តើមានលទ្ធផលអ្វីទេ? | ១. បាទ/ចាស– ត្រូវបាន ទទួលយក និងអនុវត្ត<br>២. បាទ/ចាស– ត្រូវបាន ទទួលយក មិនទាន់បាន អនុវត្ត<br>៣. ទេ – ត្រូវបានបដិសេធ<br>៤. ទេ– មិនមានចម្លើយ |
| ៣.២១ | ប្រសិនត្រូវបានអនុវត្ត តើមានរចនាសម្ព័ន្ធចំនួនប៉ុន្មានត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី? | រចនាសម្ព័ន្ធ#៖<br>___\|___\|__\| |
| ៣.២២ | តើមាននរណាម្នាក់ក្នុងសហគមន៍បានលក់ដី ឬផ្ទះសម្បែងរបស់ខ្លួនដោយសារជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែរឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣. អត់ដឹង |
| ៣.២៣ | បើមាន តើផ្ទះប៉ុន្មាន? | |
| ៣.២៤ | តើសហគមន៍មានបញ្ហាជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែរឬទេ? | |
| ៣.២៥ | បើមាន តើមានបញ្ហាអ្វីខ្លះ? | |

## ៤. ហេដ្ឋារចនាសម្ព័ន្ធ និងសេវា

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ៤.១ | តើទីតាំងលំនៅឋានបានតភ្ជាប់បណ្តាញទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញឬទេ? | ១. បាទ/ចាស<br>២. ទេ– ពីមុនមាន ប៉ុន្តែឥលូវត្រូវបានផ្តាច់<br>៣. ទេ – មិនដែលមានការតភ្ជាប់បណ្តាញ.. ) |
| ៤.២ | តើប្រព័ន្ធទឹកស្អាតបឋមណាមួយដែលទីតាំងលំនៅឋានប្រើប្រាស់? | ១. បាទ/ចាស – ឯកជនរបស់រដ្ឋ<br>២. បាទ/ចាស – សាធារណៈរបស់រដ្ឋ<br>៣. បាទ/ចាស – ដីឯកជនដែលជាកម្មសិទ្ធិរបស់យើង<br>៤. បាទ/ចាស– ដីឯកជនដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង<br>៥. មិនមានព័ត៌មាន<br>៦. មិនអនុវត្តចំពោះ (អ្នកជួល) |
| ៤.៣ | តើទីតាំងលំនៅឋានមានការភ្ជាប់បណ្តាញអគ្គិសនីរបស់អគ្គិសនីកម្ពុជាឬទេ? | ១. បាទ/ចាស<br>២. ទេ - ធ្លាប់មានពីមុន ប៉ុន្តែឥលូវផ្តាច់បាត់ហើយ<br>៣. ទេ - មិនដែលមានការភ្ជាប់បណ្តាញទេ |
| ៤.៤ | តើទីតាំងលំនៅឋានប្រើប្រាស់ប្រភពអគ្គិសនីបឋមណាមួយ? | ១. ការភ្ជាប់បណ្តាញអគ្គិសនីកម្ពុជា<br>២. អគ្គិសនីកម្ពុជាគិតតម្លៃដោយម្ចាស់លំនៅឋានជួល/ឈ្មួញកណ្តាល<br>៣. អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន<br>៤. ម៉ាស៊ីនភ្លើងឯកជន<br>៥. គ្មានអគ្គិសនី |

| | | |
|---|---|---|
| ៤.៥ | តើទឹកភ្លៀង និងលាមកទៅណា? | ១. ប្រព័ន្ធលូបង្ហូរទឹកក្រោមដី<br>២. ប្រព័ន្ធលូបង្ហូរទឹកក្រោមដី (ដូចជា ប្រឡាយ)<br>៣. ផ្ទាល់ពីលំនៅឋានចូលទៅក្នុងស្រះ/បឹង/ទន្លេ/វាលស្រែ<br>៤. មិនមានប្រព័ន្ធ<br>៥. ផ្សេងៗ |
| ៤.៦ | តើប្រព័ន្ធលូបង្ហូរទឹកដំណើរការទេ? | ១. បាទ/ចាស– ប្រព័ន្ធល្អខ្លាំងណាស់<br>២. បាទ/ចាស– ប្រព័ន្ធល្អ<br>៣. បាទ/ចាស– ប្រព័ន្ធខ្សោយ<br>៤. បាទ/ចាស– ប្រព័ន្ធខ្សោយខ្លាំងណាស់<br>៥. ទេ– ពីមុនមាន ប៉ុន្តែឥលូវមិនដំណើរការទេ |
| ៤.៧ | តើទីតាំងលំនៅឋាននេះមានភ្លើងបំភ្លឺតាមផ្លូវ/ភ្លើងបំភ្លឺតាមសហគមន៍ដែរឬទេ? | ១. បាទ/ចាស - ដំណើរការ<br>២. បាទ/ចាស - មិនដំណើរការ<br>៣. ទេ |
| ៤.៨ | តើមានសេវាកម្មប្រមូលកាកសំណល់រឹងនៅក្នុងទីតាំងលំនៅឋាននេះទេ? | ១. បាទ/ចាស<br>២. ទេ |
| ៤.៩ | ប្រសិនបើមិនមានសេវាប្រមូលកាកសំណល់រឹងទេ តើទីតាំងលំនៅឋានអាចគ្រប់គ្រងកាកសំណល់រឹងរបស់ខ្លួនបានដោយរបៀបណា? | ១. ដុតចោល<br>២. កប់ចោល<br>៣. ចាក់ចោលក្នុងតំបន់ដែលមានសេវាប្រមូលកាកសំណល់រឹង<br>៤. ចាក់ចោល (គ្មានសេវាកម្មប្រមូលសំរាម)<br>៥. ផ្សេងៗ៤.១០ |

| | | |
|---|---|---|
| ៤.១០ | តើនរណាផ្តល់សេវាកម្មប្រមូលកាកសំណល់រឹង? | ១. ក្រុមហ៊ុនស៊ីនទ្រី (CINTRI)<br>២. អង្គការកែឆ្នៃ និងអនាម័យសហគមន៍ (CSARO)<br>៣. ផ្សេងៗ |
| ៤.១១ | តើប្រជាពលរដ្ឋនៅក្នុងសហគមន៍មានប័ណ្ណក្រីក្រដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៤.១២ | តើប្រជាពលរដ្ឋនៅក្នុងសហគមន៍រាយការណ៍ពីបញ្ហាជាមួយប័ណ្ណក្រីក្រ ដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៤.១៣ | ប្រសិនបើបាទ/ចាស តើមានបញ្ហាអ្វីខ្លះ? | សូមរាយបញ្ជី |
| ៤.១៤ | តើសមាជិកសហគមន៍ធ្លាប់រាយការណ៍អំពីបញ្ហាក្នុងការសុំអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៤.១៥ | ប្រសិនបើបាទ/ចាស តើមានបញ្ហាអ្វីខ្លះ? | សូមរាយបញ្ជី |

## ៥.សិទ្ធិទទួលបានការរាប់បញ្ចូលក្នុងការធ្វើសេចក្ដីសម្រេចអំពីសហគមន៍

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ៥.១ | តើសហគមន៍ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំកសាងផែនការសង្កាត់ឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.២ | តើសហគមន៍ត្រូវបានអនុញ្ញាតឱ្យមានមតិក្នុងកិច្ចប្រជុំកសាងផែនការសង្កាត់ឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.៣ | តើសហគមន៍ធ្លាប់ទទួលបានការគំរាមកំហែងពីអាជ្ញាធរដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.៤ | ប្រសិនបើធ្លាប់ តើមានការគំរាមកំហែងអ្វីខ្លះ? | |
| ៥.៥ | តើសហគមន៍មានអារម្មណ៍ថាត្រូវបានបញ្ចូលនៅក្នុងការធ្វើសេចក្ដីសម្រេចដែលប៉ះពាល់ដល់សហគមន៍ដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.៦ | តើអាជ្ញាធរធ្លាប់ធ្វើការសន្យាជាមួយសហគមន៍ឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.៧ | បើធ្លាប់ តើពួកគេគោរពតាមការសន្យាទាំងនោះឬទេ? | ១. បាទ/ចាស<br>២. ទេ<br>៣.បានខ្លះ |
| ៥.៨ | បើសិនជាមិនគោរព តើគេមិនគោរពសន្យាអ្វីខ្លះ? | សូមរាយបញ្ជី |
| ៥.៩ | តើសហគមន៍មានអារម្មណ៍ថាមានគេរើសអើងមកលើខ្លួនដែរឬទេ? | ១. បាទ/ចាស<br>២. ទេ |
| ៥.១០ | បើសិនជាមាន តើហេតុអ្វីបានជាសហគមន៍មានអារម្មណ៍ថា គេរើសអើងមកលើខ្លួន? | |

## ៦.អនាគត

| ល.រ | សំណួរ | លេខកូដចម្លើយ |
|---|---|---|
| ៦.១ | តើមានចំណុចណាមួយជាអាទិភាពខ្ពស់សម្រាប់ទីតាំងលំនៅឋានដែរឬទេ? បើមាន តើនៅក្នុងលំដាប់មួយណា? (បោះពុម្ពឱ្យសហគមន៍ចង្អុលបង្ហាញ)<br>១. ដាក់ស្នើសុំដំណើរការប័ណ្ណកម្មសិទ្ធិដីធ្លីជាប្រព័ន្ធ<br>២. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ<br>៣. អង្គការផ្លូវការសហគមន៍<br>៤. កសាងសមត្ថភាពរបស់សមាជិកនៅទីតាំងលំនៅឋាន<br>៥. អង្គការគម្រោងសន្សំប្រាក់<br>៦. សន្តិសុខសិទ្ធិកាន់កាប់អគារសម្រាប់ទីតាំងលំនៅឋាន<br>៧. ចូលរួមក្នុងការអនុវត្តសារាចរលេខ ០៣<br>៨. ការផ្លាស់ប្តូរទីលំនៅទៅកន្លែងផ្សេង<br>៩. ផ្សេង | ១. បាទ/ចាស<br>២. ទេ |

**តើអ្នកមានសំណួរអ្វីសម្រាប់ពួកយើងទេ?**

**សូមអរគុណចំពោះការចូលរួមក្នុងការស្ទង់មតិនេះ!!**

# ៧. ឧបសម្ព័ន្ធទី២៖ ផែនទីទីតាំងលំនៅឋានក្រីក្រ




អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization - a Cambodian Urban NGO

ទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ

URBAN POOR SETTLEMENTS IN PHNOM PENH

| TOTAL SETTLEMENT | : 191 |
|---|---|
| 7 Makara | : 7 |
| Boeng Keng kang | : 4 |
| Chamkar Mon | : 5 |
| Chbar Ampov | : 27 |
| Chroy Chongva | : 8 |
| Dangkor | : 19 |
| Daun Penh | : 9 |
| Kam Buol | : 1 |
| Mean Chey | : 29 |
| Por Senchey | : 13 |
| Prek Pnov | : 10 |
| Russey Keo | : 36 |
| Sen Sok | : 12 |
| Tuol Kork | : 11 |

**7 MAKARA**
1 Angkor Meanchey
2 Phum 2*
3 Phum 4*
4 Phum 6*
5 Phum 5*
6 Phum 7*
7 Borey Keila

**BEONG KENG KANG**
8 Ponle Khemara
9 Phsar Leu*
10 Phum 5*
11 Phum 9*

**CHAMKAR MON**
12 Krom 16*
13 Wat Than
14 Krom 30*
15 Boeung Trobek Phum 4
16 Samaki Rong Roeung

**CHBAR AMPOV**
17 Tangov Krom
18 Prek Pra*
19 Russey Sroh
20 Prah Ponlea
21 Prek Kampoes
22 Kdey Takoy*
23 Boeung Chhouk Mean Chey Thmey II
24 Chamreun
25 Nirot Boeung Chhouk
26 Chmar Eut
27 Yok Bath*
28 Chroy Ampil*
29 Yok Bath*
30 Veal Sbov
31 Deum Chan*
32 Deum Sleng 1*
33 Deum Chan*
34 Deum Chan*
35 Deum Ampil*
36 Smor San
37 Deum Makloeu*
38 Prek Tleng*
39 Ou Andoung*
40 Chamreun Apiwat
41 Reak Chamreun
42 Champuh Kaek
43 Prek Thmey*

**CHROY CHONGVA**
44 Phum 2*
45 Krom 2*
46 Prek Taroth*
47 Phum 3*
48 Prek Meak
49 Deum Kor*
50 Prek Taroth*
51 Prek Takong

**DABGKOR**
52 Kdey Sangkoem Phum Kva
53 Tuol Sambo
54 Serey Deydos
55 Toek Thla
56 Bakou*
57 Tuol Sambo
58 GK community
59 Komreang*
60 Prey Sor*
61 Phum Roluos*
62 Sambok Chab Phum Mor
63 Cheung Ek Group 4
64 Cheung Ek
65 Cheung Ek Group 3
66 Phum 3
67 Srok Chek
68 Roluos Cheung Ek
69 Damnak Sangke
70 Takok

**DAUN PENH**
71 Plov Ratespleung
72 Blok Tampang
73 Phum 8*
74 Phum 3*
75 Phum 6*
76 Heam Cheat
77 Phum 9*
78 Phum 3*
79 Phum 10*

**KAM BOUL**
80 Sre Ampil Thmey

**MEAN CHEY**
81 Tuol Roka
82 Strey Apiwat Phum 5
83 Toul Roka 2*
84 Phnum Samram
85 Reaksmey Samaki
86 Sambok Chab
87 Trea 3*
88 Prek Tori*
89 Prek Tanou Reakreay
90 Krom 42*
91 Domnak Thom 1*
92 Prek Takong*
93 Tnaut Chrom
94 Tnaut Chrum Bey
95 Apiwat Commmunity
96 Prek Takong 2*
97 Prek Talong*
98 Prek Talong*
99 Prek Talong
100 Prek Talong*
101 Prek Tanou
102 Stoeng Meanchey
103 Sambok Chab 1
104 Sambok Chab 3
105 Tuol Roka
106 Prah Noreay
107 Prek Takong 1
108 Prek Takong 3
109 Prek Takong 60 Meters

**POR SENCHEY**
110 Sampor Thmey
111 Thmor Kol*
112 Samaki 5*
113 Samaki*
114 Samaki 4*
115 Samaki 1*
116 Pong Ro Senchey
117 Phum Prey Chisak
118 Ta Nguon*
119 Krom 5*
120 Krom 4*
121 Prey Sala
122 Por Prok*

**PREK PNOV**
123 Aungdong
124 Angdoung 2
125 Phsar Lech*
126 Chres Thmey
127 Angdoung 5
128 Sompor Thmey
129 Tropang Chek
130 Svay Chek Thmey
131 Pram Knorng*
132 Samrong Tbong

**RUSSEY KEO**
133 Boeung Chhouk
134 Borey Deumsral
135 Boeung Salang
136 Phum Kor 1*
137 Boeung Chhouk*
138 Boeung Salang
139 Strey Klang Sang
140 Krolkol*
141 Spean Kpuos*
142 Spean Kpuos*
143 Phum Lou*
144 Krom 7*
145 Phsar Touch AB
146 Krom 9*
147 Lor Kampor*
148 Boeung Kamyap*
149 Tonle Sab 1
150 Phum Kor*
151 Deum Por*
152 Phum 3*
153 Mithpheab*
154 Strey Klahan
155 Borey Santipheap
156 Krolkol*
157 Mittapheap
158 Ruommith
159 Deum Srol
160 Krolkol*
161 Pram Knorng*
162 Cheko
163 Krom 6
164 Svay Pak
165 Phum Lor*
166 Boeung Chhouk A
167 Boeung Chhouk
168 Stoeng Kampot

**SEN SOK**
169 Toek Thla
170 Phum Prey Mol*
171 Tumnob*
172 Kork Klang Pir*
173 Phnom Penh Thmey
174 Tropang Rang
175 Sen Suosdey
176 Sen Phunleu 2
177 Sen Phunleu 1
178 Sen Reak Reay
179 92 Community
180 Kak Sikor

**TUOL KORK**
181 Phum 23
182 Phum 21*
183 Plov Rotespleung
184 Krom 54*
185 Samaki Phum 2
186 Phum 17*
187 Klang Romsav
188 Plov Ratespleung Krom 104
189 Sahakum 102
190 Phum 7*
191 Phum 17*




សម្គាល់ **Legend**
- ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង Urban Poor Settlements
- ផ្លូវ Road
- ផ្លូវរថភ្លើង Railway
- ព្រំប្រទល់សង្កាត់ Commune boundaries
- ព្រំប្រទល់ខណ្ឌ District boundaries
- ព្រំប្រទល់រាជធានីភ្នំពេញ Phnom Penh boundary
- ផ្ទៃទឹក Water

N W E S

Coordinate System: WGS1984 UTM Zone 48N
Scal: 1: 136 000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Railway (2012), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.



Sahmakum Teang Tnaut Organization
URBAN POOR SETTLEMENTS IN TUOL KORK DISTRICT
TUOL KORK
TK01 Phum 23
TK02 Phum 21*
TK03 Plov Rotespleung
TK04 Krom 54*
TK05 Samaki Phum 2
TK06 Phum 17*
TK07 Klang Romsav
TK08 Plov Ratespleung Krom 104
TK09 Sahakum 102
TK10 Phum 17*
TK11 Phum 7*
Legend
Urban Poor Settlements
Road
Railway
Commune boundaries
District boundaries
Water
0 250 500 750
Meters
N
W E
S
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 17000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Sen Sok
Akreiy Ksatr
Por SenChey
Kamboul
TUOL KORK
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
487000
488000
489000
490000
491000
1281000
1280000
1279000
1278000
1277000
Russey Keo
Boeng Kak 1
Boeng Kak 2
TUOL KORK
Daun Penh
Sen Sok
RUPP
IFL
ITC
Phsar Depou 1
Tuek L'ak 1
Phsar Depou 2
Tuek L'ak 2
Phsar Depou 3
Tuek L'ak 3
Phsar Daeum Kor
Boeng Salang
Mean Chey
City Center Boulevard (169)
TK01
TK02
TK03
TK04
TK05
TK06
TK07
TK08
TK09
TK10
TK11


ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌដូនពេញ
URBAN POOR SETTLEMENTS IN DAUN PENH DISTRICT
Sahmakum Teang Tnaut Organization - a Cambodian Urban NGO
DAUN PENH
DP01 Plov Ratespleung
DP02 Blok Tampang
DP03 Phum 6*
DP04 Heam Cheat
DP05 Phum 9*
DP06 Phum 3*
DP07 Phum 10*
DP08 Phum 8*
DP09 Phum 3*
សម្គាល់
Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវរថភ្លើង
Railway
ផ្លូវ
Road
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0 250 500 750
Meters
N W E S
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 14000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Akreiy Ksatr
Sen Sok
Tuol Kouk
Por SenChey
DAUN PENH
Kamboul
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
490000
491000
492000
493000
1281000
1280000
1279000
1278000
Russey Keo
DAUN PENH
Srah Chak
Voat Phnum
Chroy Chongva
DP01
DP02
DP03
DP04
DP05
DP06
DP07
DP08
DP09
Phsar Kandal 1
Phsar Kandal 2
Phsar Thmei 1
Phsar Thmei 2
Phsar Thmei 3
Tuol Kouk
7 Makara
National Museum
Chey Chummeah
Royal Palace
Boeng Reang
Chakto Mukh
City Center Boulevard (169)







អង្គការសហគមន៍ទាំងត្នោត

Sahmakum Teang Tnaut Organization - a Cambodian Urban NGO

# ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌ៧មករា

# URBAN POOR SETTLEMENTS IN 7 MAKARA DISTRICT

**7 MAKARA**

7M01 Angkor Meanchey
7M02 Phum 2(*)
7M03 Phum 4(*)
7M04 Phum 6(*)
7M05 Phum 5(*)
7M06 Phum 7(*)
7M07 Borey Keila

## សម្គាល់ Legend

- ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង / Urban Poor Settlements
- ផ្លូវ / Road
- ផ្លូវរថភ្លើង / Railway
- ព្រំប្រទល់សង្កាត់ / Commune boundaries
- ព្រំប្រទល់ខណ្ឌ / District boundaries
- ផ្ទៃទឹក / Water

0 100 200 300
Meters

N W E S

Coordinate System: WGS1984 UTM Zone 48N
Scal: 1: 6800
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.



ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌច្បារអំពៅ
URBAN POOR SETTLEMENTS IN CHBAR AMPOV DISTRICT
Sahmakum Teang Tnaut Organization
CHBAR AMPOV
CA01 Tangov Krom
CA02 Prek Pra*
CA03 Russey Sros
CA04 Prah Ponlea
CA05 Prek Kampoes
CA06 Kdey Takoy*
CA07 Boeung Chhouk Meanchey Thmey 2
CA08 Chamreun
CA09 Nirot Boeung Chhouk
CA10 Chma Aoet
CA11 Yok Bath*
CA12 Chroy Ampil*
CA13 Yok Bath*
CA14 Veal Sbov
CA15 Deum Chan*
CA16 Deum Sleng 1*
CA17 Deum Chan*
CA18 Deum Chan*
CA19 Deum Ampil*
CA20 Smor San
CA21 Deum Makloeu*
CA22 Prek Tleng*
CA23 Ou Andoung*
CA24 Chamreun Apiwat
CA25 Reak Chamreun
CA26 Tomnob Ta Thlan
CA27 Andoung Ta Eang
សម្គាល់
Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវ
Roads
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0 700 1,400 2,100
Meters
N
W
E
S
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 42000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Akreiy Ksatr
Sen Sok
Tuol Kouk
Por SenChey
Chamkar Mon
Mean Chey
CHBAR AMPOV
Dang Kor
Ta Khmau
Kandal Stueng
Kong Pisei
492000
496000
500000
504000
1276000
1272000
1268000
Daun Penh
Chroy Chongva
Akreiy Ksatr
Chamkar Mon
Chbar Ampov Ti Pir
Chbar Ampov Ti Muoy
Nirouth
Veal Sbov
Kbal Kaoh
Preaek Aeng
Preaek Pra
Mean Chey
CHBAR AMPOV
Kien Svay
Preaek Thmei
Ta Khmau
CA01
CA03
CA04
CA05
CA06
CA08
CA09
CA10
CA11
CA12
CA13
CA14
CA16
CA18
CA19
CA20
CA22
CA23
CA24
CA25
CA26
CA27


Sahmakum Teang Tnaut Organization - a Cambodian Urban NGO
ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌមានជ័យ
URBAN POOR SETTLEMENTS IN MEAN CHEY DISTRICT
MEAN CHEY
MC01 Tuol Roka
MC02 Strey Apiwat Phum 5
MC03 Toul Roka 2*
MC04 Phnum Samram
MC05 Reaksmey Samaki
MC06 Sambok Chab
MC07 Trea 3*
MC08 Prek Torl*
MC09 Prek Tanou Reakreay
MC10 Krom 42*
MC1 Domnak Thom 1*
MC12 Tnaut Chrom
MC13 Prek Takong*
MC14 Tnaut Chrom 3
MC15 Apiwat Commmunity
MC16 Prek Takong 2*
MC17 Prek Talong*
MC18 Prek Talong*
MC19 Prek Talong
MC20 Prek Talong*
MC21 Prek Tanou
MC22 Stoeng Meanchey
MC23 Sambok Chab 1
MC24 Sambok Chab 3
MC25 Tuol Roka
MC26 Prah Noreay
MC27 Prek Takong 1
MC28 Prek Takong 3
MC29 Prek Takong 60m
សម្គាល់
Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវ
Road
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0 500 1,000 1,500
Meters
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 30000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Akreiy Ksatr
Sen Sok
Tuol Kouk
Por SenChey
Chamkar Mon
MEAN CHEY
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
Tuol Kouk
Sen Sok
Boeng Keng Kang
Stueng Meanchey 1
Chamkar Mon
Stueng Meanchey 3
Stueng Meanchey 2
Boeng Tumpun 1
Por SenChey
Boeng Tumpun 2
Chak Angrae Leu
Chbar Ampov
MEAN CHEY
Chak Angrae Kraom
Dang Kor
Ta Khmau
486000
488000
490000
492000
494000
1276000
1274000
1272000
1270000



Sahmakum Teang Tnaut Organization
URBAN POOR SETTLEMENTS IN RUSSEY KEO DISTRICT
RUSSEY KEO
RSK01 Boeung Chhouk
RSK02 Borey Deumsral
RSK03 Boeung Salang
RSK04 Phum Kor 1*
RSK05 Boeung Chhouk*
RSK06 Boeung Salang
RSK07 Strey Klang Sang
RSK08 Krolkol*
RSK09 Spean Kpuos*
RSK10 Spean Kpuos*
RSK11 Phum Lou*
RSK12 Krom 7*
RSK13 Phsar Touch AB
RSK14 Krom 9*
RSK15 Lor Kampor*
RSK16 Boeung Kamyap*
RSK17 Tonle Sab 1
RSK18 Phum Kor*
RSK19 Deum Por*
RSK20 Phum 3*
RSK21 Mithpheap*
RSK22 Strey Klahan
RSK23 Borey Santipheap
RSK24 Krolkol*
RSK25 Mittapheap
RSK26 Ruommith
RSK27 Deum Srol
RSK28 Krolkol*
RSK29 Pram Knorng*
RSK30 Cheko
RSK31 Krom 6
RSK32 Svay Pak
RSK33 Phum Lor*
RSK34 Boeung Chhouk A
RSK35 Boeung Chhouk
RSK36 Stoeng Kambot
Legend
Urban Poor Settlements
Road
Commune boundaries
District boundaries
Water
0 100 200 300
Meters
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 30000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Sen Sok
Akreiy Ksatr
Tuol Kouk
Por SenChey
Chamkar Mon
Chbar Ampov
Dang Kor
Ta Khmau
Kong Pisei
Kandal Stueng
Svay Pak
Chrang Chamreh Ti Muoy
Chrang Chamreh Ti Pir
Kilometer Lek 6
Russey Keo
Tuol Sangke Ti Pir
Tuol Sangke Ti Muoy
484000
486000
488000
490000
492000
1288000
1286000
1284000
1282000







Sahmakum Teang Tnaut Organization - a Cambodian Urban NGO

# ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌចំការមន

# URBAN POOR SETTLEMENTS IN CHAMKAR MON DISTRICT

**CHAMKAR MON**

CMN01 Krom 16*
CMN02 Wat Than
CMN03 Krom 30*
CMN04 Boeung Trobek Phum 4
CMN05 Samaki Rong Roeung

**សម្គាល់ Legend**

ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង Urban Poor Settlements
ផ្លូវ Roads
ព្រំប្រទល់សង្កាត់ Commune boundaries
ព្រំប្រទល់ខណ្ឌ District boundaries
ផ្ទៃទឹក Water

N W E S

0 250 500 750 1,000
Meters

Coordinate System: WGS1984 UTM Zone 48N
Scal: 1: 15800
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.



ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌសែនសុខ
URBAN POOR SETTLEMENTS IN SEN SOK DISTRICT
Sahmakum Teang Tnaut Organization
SEN SOK
SS01 Toek Thla
SS02 Phum Prey Mol*
SS03 Tumnob*
SS04 Kork Klang 2*
SS05 Phnom Penh Thmey
SS06 Tropang Rang
SS07 Sen Suosdey
SS08 Sen Punleu 2
SS09 Sen Punleu 1
SS10 Sen Reak Reay
SS11 Kao Pi
SS12 Kak Sikor
សម្គាល់
Legend
Urban Poor Settlements
Road
Railway
Commune boundaries
District boundaries
Water
0 100 200 300
Meters
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 42000
Date:14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
480000
483000
486000
489000
1287000
1284000
1281000
1278000
Prek Pnov
Khmuonh
Krang Thnong
Kouk Khleang
Phnom Penh Thmei
Russey Keo
Chroy Chongva
Tuol Kouk
Por SenChey
Mean Chey
City Center Boulevard (169)
Ponhea Lueu
Prek Pnov
Chroy Chongva
Russey Keo
SEN SOK
Tuol Kouk
Angk Snuol
Por SenChey
Chamkar Mon
Mean Chey
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
Kong Pisei


ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌព្រែកព្នៅ
URBAN POOR SETTLEMENTS IN PREK PNOV DISTRICT
Sahmakum Teang Tnaut Organization - a Cambodian Urban NGO
PREK PNOV
PPN01 Aungdong
PPN02 Aungdong 2
PPN03 Phsar Lech*
PPN04 Chres Thmey
PPN05 Angdoung 5
PPN06 Sompor Thmey
PPN07 Tropang Chek
PPN08 Svay Chek Thmey
PPN09 Pram Knorng*
PPN10 Samrong Tbong
សម្គាល់ Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវ
Roads
ផ្លូវរថភ្លើង
Railway
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0 1,000 2,000 3,000
Meters
N E S W
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 57,000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
PREK PNOV
Russey Keo
Akreiy Ksatr
Sen Sok
Tuol Kouk
Por SenChey
Chamkar Mon
Kamboul
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
Kong Pisei
470000
475000
480000
485000
1295000
1290000
1285000
1280000
Ponhea Lueu
Samraong
Chroy Chongva
Win Win Boulevard
Ponhea Pon
PREK PNOV
Angk Snuol
Ponsang
Kouk Roka
Russey Keo
Sen Sok
Kamboul
Por SenChey
PP01
PP02
PP03
PP04
PP05
PP06
PP07
PP08
PP09
PP10



477000
480000
483000
486000
1281000
1278000
1275000
1272000
Prek Pnov
Samraong Kraom
Sen Sok
Kakab 2
Kakab 1
POR SENCHEY
International Airport
Kamboul
Chaom Chau 3
Chaom Chau 2
Chaom Chau 1
Dang Kor
PSC01
PSC02
PSC03
PSC04
PSC05
PSC06
PSC07
PSC08
PSC09
PSC11
PSC12
PSC13
Ponhea Lueu
Chroy Changva
Prek Pnov
Russey Keo
Akreiy Ksatr
Sen Sok
Daun Penh
POR SENCHEY
Chamkar Mon
Kamboul
Chbar Ampov
Dang Kor
Ta Khmau
Kong Pisei
Kandal Stueng
Sahmakum Teang Tnaut Organization
ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌពោធិ៍សែនជ័យ
URBAN POOR SETTLEMENTS IN POR SENCHEY DISTRICT
POR SENCHEY
PSC01 Sampor Thmey
PSC02 Thmor Kol*
PSC03 Samaki 5*
PSC04 Samaki*
PSC05 Samaki 4*
PSC06 Samaki 1*
PSC07 Pong Ro Senchey
PSC08 Prey Chisak
PSC09 Ta Nguon*
PSC10 Krom 5*
PSC11 Krom 4*
PSC12 Prey Sala
PSC13 Por Prok*
សម្គាល់
Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវ
Road
ផ្លូវរថភ្លើង
Railway
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0
70
140
210
Meters
N
W
E
S
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 43000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.



ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌជ្រោយចង្វា
URBAN POOR SETTLEMENTS IN CHROY CHANGVA DISTRICT
Sahmakum Teang Tnaut Organization
CHROY CHONGVA
CC01 Phum 2*
CC02 Krom 2*
CC03 Prek Taroth*
CC04 Phum 3*
CC05 Prek Meak
CC06 Deum Kor*
CC07 Prek Taroth*
CC08 Prek Takong
សម្គាល់
Legend
ទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង
Urban Poor Settlements
ផ្លូវ
Road
ផ្លូវរថភ្លើង
Railway
ព្រំប្រទល់សង្កាត់
Commune boundaries
ព្រំប្រទល់ខណ្ឌ
District boundaries
ផ្ទៃទឹក
Water
0 100 200 300
Meters
N E S W
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 70000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
CHROY CHANGVA
Ponhea Lueu
Bak Kaeng
Khsach Kandal
Kaoh Dach
Preak Ta Sek
Preak Lieb
Prek Pnov
RUSSEY KEO
Russey Keo
Akreiy Ksatr
Sen Sok
Chroy Chongva
Tuol Kouk
Daun Penh
Por SenChey
7 Makara
Win Win Boulevard
7NG Road
CC01
CC02
CC03
CC04
CC05
CC06
CC08
Prek Pnov
Russey Keo
Sen Sok
Tuol Kouk
Akreiy Ksatr
Por SenChey
Chamkar Mon
Kamboul
Chbar Ampov
Dang Kor
Ta Khmau
Kandal Stueng
480000
486000
492000
498000
1296000
1290000
1284000
1278000



480000
484000
488000
492000
1272000
1268000
1264000
Por SenChey
Mean Chey
Kamboul
Prey Sa
Dangkor
Pong Tuek
Prey Veaeng
Choeung Ek
Spean Thma
DANGKOR
Sak Sampov
Tien
Roluos
Kong Noy
Preaek Kampues
Kandal Stueng
DK01
DK02
DK03
DK04
DK05
DK06
DK07
DK08
DK09
DK10
DK11
DK12
DK13
DK14
DK15
DK16
DK17
DK18
DK19
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Sen Sok
Tuol Kouk
Angk Snuol
Por SenChey
Chamkar Mon
Kamboul
Mean Chey
DANGKOR
Kong Pisei
Kandal Stueng
Sahmakum Teang Tnaut Organization
URBAN POOR SETTLEMENTS IN DANGKOR DISTRICT
DANGKOR
DK01 Kdey Sangkoem Phum Kva
DK02 Tuol Sambo
DK03 Serey Deydos
DK04 Toek Thla
DK05 Bakou*
DK06 Tuol Sambo
DK07 GK community
DK08 Komreang*
DK09 Prey Sor*
DK10 Phum Roluos*
DK11 Sambok Chab Phum Mor
DK12 Cheung Ek Group 4
DK13 Cheung Ek
DK14 Cheung Ek Group 3
DK15 Phum 3
DK16 Srok Chek
DK17 Roluos Cheung Ek
DK18 Damnak Sangke
DK19 Takok
Legend
Urban Poor Settlements
Road
Railway
Commune boundaries
District boundaries
Water
N
W
E
S
0
100
200
300
Meters
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 46000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.


Sahmakum Teang Tnaut Organization - a Cambodian Urban NGO
URBAN POOR SETTLEMENTS IN
BOENG KENG KANG DISTRICT
BOENG KENG KANG
BKK01 Ponle Khemara
BKK02 Phsar Leu*
BKK03 Phum 5*
BKK04 Phum 9*
Legend
Urban Poor Settlements
Road
Commune boundaries
District boundaries
Water
N
W
E
S
0
40
80
120
Meters
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 17000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
Ponhea Lueu
Chroy Chongva
Prek Pnov
Russey Keo
Sen Sok
Akreiy Ksatr
Tuol Kouk
Por SenChey
BOENG KENG KANG
Kamboul
Chbar Ampov
Ta Khmau
Kandal Stueng
489000
490000
491000
492000
1278000
1277000
1276000
7 Makara
Daun Penh
Tuol Kouk
Tuol Svay Prey 2
Olympic
Boeng Keng Kang 2
BKK03
BKK04
Boeng Keng Kang 1
BKK02
Tuol Svay Prey 1
BOENG KENG KANG
Boeng Keng Kang 3
BKK01
Tumnob Tuek
Chamkar Mon
Mean Chey



ទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌកំបូល
URBAN POOR SETTLEMENTS IN KAM BOUL DISTRICT
KAM BOUL
KB01 Sre Ampil Thmey
Sahmakum Teang Tnaut Organization
សម្គាល់
Legend
Urban Poor Settlements
Road
Railway
Commune boundaries
District boundaries
Water
Meters
0
100
200
300
400
N
E
S
W
Coordinate System: WGS1984 UTM Zone 48N
Scal: 1: 66000
Date: 14 July 2023
Sources: STT (urban poor settlements 2022); EZ (adminstrative boundary 2019); ODC: Railway (2012), Roads (2023), Water (2016).
Noted: (*) This is not the community site. The name of this location will be referred to by their address.
KAM BOUL
KB01
Prek Pnov
Snaor
Ovlaok
Kamboul
Angk Snuol
Kantaok
Phleung Chheh Roteh
Boeng Thum
Prateah Lang
Kandal Stueng
Sen Sok
Por SenChey
Dang Kor
Ponhea Lueu
Chroy Chongva
Russey Keo
Tuol Kouk
Chamkar Mon
Mean Chey
Ta Khmau
Kong Pisei
468000
474000
480000
486000
1278000
1272000
1266000



អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO


សម្រាប់ព័ត៌មានបន្ថែម៖

អាសយដ្ឋាន៖ ផ្ទះលេខ៧ ផ្លូវលេខ៤៩៤ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ៤៣១ ៥៥៥

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org and www.urbanvoicecambodia.net

ហ្វេសប៊ុក៖ https://www.facebook.com/sttcambodia/